អាជ្ញាធរអគ្គិសនីកម្ពុជា
ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា

# អាជ្ញាប័ណ្ណរួមសំរាប់ធ្វើសេវាកម្មផលិត បញ្ជូន និងចែកចាយអគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០០២

# ផ្នែកទី១

# សេចក្តីសំរេចផ្តល់អាជ្ញាប័ណ្ណរួមអោយអគ្គិសនីកម្ពុជា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ឯកសារអាជ្ញាប័ណ្ណលេខ ០០១ ឯអ
# អាជ្ញាប័ណ្ណរួមសំរាប់អគ្គិសនីកម្ពុជា

## អាជ្ញាធរអគ្គិសនីកម្ពុជា

- អនុវត្តតាមមាត្រា ៧ និង ៣០ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ ២០០១ ។
- យោងពាក្យស្នើសុំអាជ្ញាប័ណ្ណរួមរបស់អគ្គិសនីកម្ពុជាលេខ ២៩២៤ លស,អក ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០០១ ។
- យោងតាមការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងសាធារណជន ដែលបានធ្វើចាប់ពីថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០០១ ដល់ថ្ងៃទី ១៧ ខែមករា ឆ្នាំ ២០០២ ។
- យោងតាមការអនុម័តរបស់សម័យប្រជុំ **អាជ្ញាធរអគ្គិសនីកម្ពុជា** លើកទី៣ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០២

## សេចក្តីសំរេច

**ប្រការ១**

ផ្តល់ **អាជ្ញាប័ណ្ណរួម** ជូនក្រុមហ៊ុនទទួលខុសត្រូវមានកំណត់មួយរបស់រដ្ឋ មានឈ្មោះថា " **អគ្គិសនីកម្ពុជា** " ដែលបានបង្កើតឡើងដោយព្រះរាជក្រឹត្យ លេខ ជស/០៣៩៦/១០ ចុះថ្ងៃទី៩ ខែមិនា ឆ្នាំ ១៩៩៦ ។ អាជ្ញាប័ណ្ណរួមនេះរួមមានអាជ្ញាប័ណ្ណដូចខាងក្រោម :

(ក)- **អាជ្ញាប័ណ្ណផលិតកម្ម** សំរាប់ផ្តល់សិទ្ធិឱ្យអគ្គិសនីកម្ពុជាធ្វើសេវាកម្មផលិតកម្មអគ្គិសនីដើម្បីផ្គត់ផ្គង់អគ្គិសនីឱ្យប្រព័ន្ធបញ្ជូន និងប្រព័ន្ធចែកចាយរបស់ខ្លួន ក្នុងរយៈពេលដែលកំណត់ ដោយប្រការ៣ផ្នែកទី១ ខាងក្រោម ដោយត្រូវគោរពតាមល័ក្ខ ខ័ណ្ឌនានារបស់អាជ្ញាប័ណ្ណ ដែលមានចែងក្នុងផ្នែកទី២របស់ អាជ្ញាប័ណ្ណនេះ

(ខ)- **អាជ្ញាប័ណ្ណបញ្ជូនសំរាប់បណ្តាញជាតិបញ្ជូនអគ្គិសនី** សំរាប់ផ្តល់សិទ្ធិឱ្យអគ្គិសនីកម្ពុជាធ្វើសេវាកម្មបញ្ជូនអគ្គិសនីផ្គត់ផ្គង់ឱ្យប្រព័ន្ធចែកចាយអគ្គិសនី និងអ្នកប្រើប្រាស់អគ្គិសនីធំៗក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា លើកលែងតែក្នុងតំបន់ដែលផ្គត់ផ្គង់ដោយប្រព័ន្ធទោល ដូចមានចែងក្នុងមាត្រា៣៥ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងលើកលែងតែក្នុងករណីមានការផ្តល់សិទ្ធិ ដោយឡែកឱ្យអគ្គិសនីកម្ពុជាបញ្ជូនសំរាប់គោលបំណងពិសេសដូចមានចែងក្នុងមាត្រា៣៣របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេលដែលកំណត់ដោយប្រការ៣ ផ្នែកទី១ខាងក្រោម ដោយត្រូវគោរពតាមល័ក្ខខ័ណ្ឌនានារបស់អាជ្ញាប័ណ្ណ ដែលមានចែងក្នុងផ្នែកទី២របស់អាជ្ញាប័ណ្ណនេះ។

(គ)- **អាជ្ញាប័ណ្ណចែកចាយ** សំរាប់ផ្តល់សិទ្ធិឱ្យអគ្គិសនីកម្ពុជាធ្វើសេវាកម្មចែកចាយ និងលក់អគ្គិសនីឱ្យអ្នកប្រើប្រាស់ក្នុងតំបន់ចែកចាយដែលកំណត់ក្នុងឧបសម្ព័ន្ធទី២នៃផ្នែកទី២របស់អាជ្ញាប័ណ្ណ នេះក្នុងរយៈពេលដែលកំណត់ដោយប្រការ៣ផ្នែកទី១ ខាងក្រោម ដោយត្រូវគោរពតាមល័ក្ខខ័ណ្ឌនានារបស់អាជ្ញាប័ណ្ណ ដែលមានចែងក្នុងផ្នែកទី២របស់អាជ្ញាប័ណ្ណនេះ ។

**ប្រការ២**

លក្ខខណ្ឌនានារបស់អាជ្ញាប័ណ្ណនេះអាចកែសំរួល ឬ ធ្វើវិសោធនកម្មបានអនុលោមតាមបទប្បញ្ញត្តិរបស់អាជ្ញាប័ណ្ណនេះ ឬតាមមាត្រា ៧ និង ៤៤ របស់ ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ។ អាជ្ញាប័ណ្ណនីមួយៗដែលផ្តល់ឱ្យនេះអាចដកហូតបានស្របតាមលក្ខខណ្ឌ ដែលកំណត់ក្នុងឧបសម្ព័ន្ធទី៣ នៃផ្នែកទី២របស់អាជ្ញាប័ណ្ណនេះ ។

**ប្រការ៣**

អាជ្ញាប័ណ្ណនីមួយៗដែលបានផ្តល់ឱ្យនេះត្រូវចូលជាធរមាន នៅពេលចេញអាជ្ញាប័ណ្ណរួមនេះ និងត្រូវបន្តនៅជាធរមានរហូតដល់មានការជូនដំណឹងពីការបញ្ចប់អាជ្ញាប័ណ្ណរួមនេះ ដោយអាជ្ញាធរអគ្គិសនីកម្ពុជាជាលាយលក្ខណ៍អក្សរទៅឱ្យអគ្គិសនីកម្ពុជាដើម្បីបំបែកសេវាកម្មផលិត បញ្ជូន និងចែកចាយឱ្យចេញពីគ្នាក្នុងទីតាំងផ្តល់សេវាកម្មរបស់អគ្គិសនីកម្ពុជាតាមការកំណត់ក្នុងមាត្រា៣៥របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជាលើកលែងតែត្រូវបានដកហូតដោយអនុលោមតាមលក្ខខណ្ឌកំណត់ក្នុងឧបសម្ព័ន្ធទី៣ នៃ ផ្នែកទី២ របស់អាជ្ញាប័ណ្ណនេះ ។

ភ្នំពេញ, ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០០២

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

# ផ្នែកទី២

# ល័ក្ខខ័ណ្ឌរបស់អាជ្ញាប័ណ្ណ

# តារាងមាតិកា

**ជំពូកទី១: ភាតព្វកិច្ចទូទៅរបស់អគ្គិសនីកម្ពុជា**

លក្ខខណ្ឌទី១ : កាតព្វកិច្ចគោរពច្បាប់ អនុក្រឹត្យ និងសេចក្តីសំរេចនានា

លក្ខខណ្ឌទី២ : កាតព្វកិច្ចគោរពលក្ខខណ្ឌអាជីវកម្ម

លក្ខខណ្ឌទី៣ : កាតព្វកិច្ចធ្វើរបាយការណ៍ហិរញ្ញវត្ថុរបស់អគ្គិសនីកម្ពុជា

លក្ខខណ្ឌទី៤ : កាតព្វកិច្ចក្នុងការទិញថាមពលអគ្គិសនី

លក្ខខណ្ឌទី៥ : កាតព្វកិច្ចក្នុងការការពារសុខភាព និងសុវត្ថិភាពនៃអ្នកធ្វើការ

លក្ខខណ្ឌទី៦ : កាតព្វកិច្ចផ្តល់ពត៌មានដល់អាជ្ញាធរអគ្គិសនីកម្ពុជា

លក្ខខណ្ឌទី៧ : កាតព្វកិច្ចបង់កំរៃអាជ្ញាប័ណ្ណ

**ជំពូកទី២: លក្ខខណ្ឌសំរាប់អាជ្ញាប័ណ្ណផលិតកម្ម**

លក្ខខណ្ឌទី១ : លក្ខខណ្ឌចំពោះមធ្យោបាយផលិតកម្ម

លក្ខខណ្ឌទី២ : លក្ខខណ្ឌចំពោះកិច្ចដំណើរការផលិតកម្ម

លក្ខខណ្ឌទី៣ : ការគោរពក្រូដប្រព័ន្ធបញ្ជូន និងក្រូដប្រព័ន្ធចែកចាយ

**ជំពូកទី៣: លក្ខខណ្ឌសំរាប់អាជ្ញាប័ណ្ណបញ្ជូន**

លក្ខខណ្ឌទី១ : លក្ខខណ្ឌរៀបចំក្រូដប្រព័ន្ធបញ្ជូន

លក្ខខណ្ឌទី២ : ស្តង់ដាសន្តិសុខប្រព័ន្ធបញ្ជូន និងគុណភាពនៃសេវា

លក្ខខណ្ឌទី៣ : លក្ខខណ្ឌគោរពក្រូដប្រព័ន្ធចែកចាយ

លក្ខខណ្ឌទី៤ : ការបោះបង់ចោលអចលនទ្រព្យអាជីវកម្ម

លក្ខខណ្ឌទី៥ : ការកំរិតព្រំដែននៃការប្រើប្រាស់ពត៌មានមួយចំនួននៃអាជីវកម្មបញ្ជូនអគ្គិសនី និងឯករាជ្យភាពរបស់វា

លក្ខខណ្ឌទី៦ : លក្ខខណ្ឌបញ្ឈប់ដំណើរការប្រព័ន្ធបញ្ជូន

**ជំពូកទី៤: លក្ខខណ្ឌសំរាប់អាជ្ញាប័ណ្ណចែកចាយ**

លក្ខខណ្ឌទី១ : ស្តង់ដាការពារមិនឱ្យខ្វះខាតផលិតកម្មអគ្គិសនី

លក្ខខណ្ឌទី២ : ស្តង់ដាធ្វើផែនការប្រព័ន្ធចែកចាយ និងគុណភាពនៃសេវា

លក្ខខណ្ឌទី៣ : សន្តិសុខ និងសុវត្ថិភាពនៃការផ្គត់ផ្គង់

លក្ខខណ្ឌទី៤ : ការការពារ និងការទប់ទល់ចំពោះការលួច ការប៉ះពាល់ និងការធ្វើឱ្យខូចនាឡិកាស្ទង់

លក្ខខណ្ឌទី៥ : លក្ខខណ្ឌរៀបចំក្រូដប្រព័ន្ធចែកចាយ

លក្ខខណ្ឌទី៦ : ស្តង់ដាប្រតិបត្តិ

លក្ខខណ្ឌទី៧ : នីតិវិធីដោះស្រាយពាក្យបណ្តឹង

លក្ខខណ្ឌទី៨ : ការបោះបង់ចោលអចលនទ្រព្យ

លក្ខខណ្ឌទី៩ : ការគោរពក្រូដប្រព័ន្ធបញ្ជូន

លក្ខខណ្ឌទី១០: ការគោរពវិធានស្តីពីលក្ខខណ្ឌនៃការផ្គត់ផ្គង់

**ជំពូកទី៥: លក្ខខណ្ឌនៃការតភ្ជាប់ និងការផ្គត់ផ្គង់សំរាប់អាជ្ញាប័ណ្ណបញ្ជូន និងអាជ្ញាប័ណ្ណចែកចាយ**

លក្ខខណ្ឌទី១ : លក្ខខណ្ឌជាមូលដ្ឋានសំរាប់ផ្គត់ផ្គង់ និងលក់អគ្គិសនីឱ្យអ្នកចែកចាយមួយទៀត ឬ អ្នកប្រើប្រាស់ដុំ

លក្ខខណ្ឌទី២ : ការមិនរើសអើងក្នុងការផ្គត់ផ្គង់អគ្គិសនី និងតភ្ជាប់ជាមួយប្រព័ន្ធ

លក្ខខណ្ឌទី៣ : ការទាមទារផ្តល់លក្ខខណ្ឌកិច្ចសន្យា

លក្ខខណ្ឌទី៤ : ស្តង់ដាលក្ខខណ្ឌនៃការតភ្ជាប់ និងការផ្គត់ផ្គង់សំរាប់ អ្នកចែកចាយផ្សេងទៀត និងអ្នកប្រើប្រាស់ដុំ

លក្ខខណ្ឌទី៥ : ភារកិច្ចរបស់អាជ្ញាធរអគ្គិសនីកម្ពុជា

**ឧបសម្ព័ន្ធទី១** : មធ្យោបាយផលិតកម្មដែលមានស្រាប់របស់អគ្គិសនីកម្ពុជា

**ឧបសម្ព័ន្ធទី២** : តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនី

**ឧបសម្ព័ន្ធទី៣** : លក្ខខណ្ឌសំរាប់ធ្វើការដកហូតអាជ្ញាប័ណ្ណ

**និយមន័យនៃពាក្យដែលប្រើក្នុងលក្ខខណ្ឌនៃអាជ្ញាប័ណ្ណរបស់សំរាប់អគ្គិសនីកម្ពុជា**

ពាក្យពេចន៍ទាំងឡាយណាដែលបានប្រើប្រាស់ក្នុងឯកសារអាជ្ញាប័ណ្ណនេះ ឬផ្នែកណាមួយរបស់ឯកសារនេះ និងនៅក្នុងឧបសម្ព័ន្ធភ្ជាប់ ប្រសិនបើពុំមានការបញ្ជាក់ខ្លឹមសារផ្សេងទេ ត្រូវមានន័យដូចខាងក្រោម :

"ថាមពលសកម្ម" មានន័យថា ថាមពលអគ្គិសនីដែលបានផលិត ឆ្លងកាត់ ឬ ផ្គត់ផ្គង់ដោយសៀគ្វីអគ្គិសនីមួយក្នុងរយៈពេលកំណត់មួយ (គឺជាការគុណបញ្ចូលគ្នានៃអានុភាពតាមពេលជាមួយរយៈពេល) ដែលវាស់វែងដោយឯកតារង្វាស់គិតជាវ៉ាត់ម៉ោង (Wh) និងពហុគុណរបស់វាដូចជា :

1,000 Wh = ១ គីឡូវ៉ាត់មោង (kWh)

1,000 kWh = ១ មេហ្គាវ៉ាត់ម៉ោង (MWh)

1,000 MWh = ១ ជីហ្គាវ៉ាត់ម៉ោង (GWh)

1,000 GWh = ១ តេរ៉ាវ៉ាត់ម៉ោង (TWh)

"សវនកម្ម" មានន័យថា ការជំរះបញ្ជីលើរបាយការណ៍ហិរញ្ញវត្ថុ របស់អគ្គិសនីកម្ពុជាដោយសវនករណាមួយក្នុងរយៈពេលធ្វើអាជីវកម្ម ។

"អនុញ្ញាត" ឱ្យធ្វើអាជីវកម្ម ឬ ធ្វើសកម្មភាពណាមួយមានន័យថា ការអនុញ្ញាតដោយអាជ្ញាប័ណ្ណដែលបានផ្តល់ឱ្យស្របតាមច្បាប់នេះ ។

"លក្ខខណ្ឌ" មានន័យថា ជាលក្ខខណ្ឌចែងក្នុងអាជ្ញាប័ណ្ណនេះ ។

"ថ្លៃភ្ជាប់ប្រព័ន្ធ" មានន័យថា ជាបន្ទុកត្រូវបង់ថ្លៃចំណាយសំរាប់ការអនុវត្តនីការងារ ការផ្តល់សំភារៈ និងការតំលើងនៃបរិក្ខាអគ្គិសនី ខ្សែបណ្តាញអគ្គិសនី និងនាឡិកាស្ទង់ផ្ទៃក្នុង ក្នុងការសាងសង់ ឬការកែសំរួលចំណុច ដែលត្រូវភ្ជាប់ចូល និងភ្ជាប់ចេញនៃប្រព័ន្ធបញ្ជូនអគ្គិសនី និង ប្រព័ន្ធចែកចាយអគ្គិសនីរបស់អគ្គិសនីកម្ពុជា ។

"អ្នកប្រើប្រាស់" មានន័យថា ជាបុគ្គលណាមួយ ឬ អ្នកទទួលសិទ្ធិបន្ត ដែលទិញ ឬ ទទួលអគ្គិសនីដើម្បីប្រើប្រាស់ និងមិនមែនដើម្បីផ្តល់ ឬ លក់បន្តឱ្យអ្នកដទៃទៀតឡើយ។

"**អ្នកប្រើប្រាស់ធុនតូច**" គឺអ្នកប្រើប្រាស់ជាលំនៅដ្ឋានឬ អ្នកប្រើប្រាស់ ដែលមានបរិមាណ ប្រើប្រាស់មិនលើសពី ១២០០០ គីឡូវ៉ាត់ម៉ោងក្នុង ១ឆ្នាំ ។

"**អ្នកប្រើប្រាស់ធុនធំ**" គឺជាអ្នកប្រើប្រាស់ ដែលទទួលការ ផ្គត់ផ្គង់ពីប្រព័ន្ធចែកចាយ និង មានបរិមាណប្រើប្រាស់លើសពី ១២០០០ គីឡូវ៉ាត់ម៉ោងក្នុង ១ឆ្នាំ ។

"**អ្នកប្រើប្រាស់ជុំ** " គឺជាអ្នកប្រើប្រាស់ ដែលទទួលការផ្គត់ផ្គង់អគ្គិសនីពីប្រព័ន្ធបញ្ជូន ។

"អតិថិជន" មានន័យថា គឺជាបុគ្គលណាមួយដែលបានទទួលការ ផ្គត់ផ្គង់ ឬ ទាមទារឱ្យមានការផ្គត់ផ្គង់អគ្គិសនីឱ្យទីតាំងខ្លួនក្នុងតំបន់អនុញ្ញាត ។

"អាជីវកម្មចែកចាយ " មានន័យថាគឺជាការធ្វើអាជីវកម្មរបស់អគ្គិសនីកម្ពុជា ចែកចាយឬសាខាណាមួយ ឬមានលក្ខណៈជា :

(ក)-ការចែកចាយអគ្គិសនីតាមរយៈប្រព័ន្ធចែកចាយរបស់អគ្គិសនីកម្ពុជាគិតរួមទាំងអាជីវកម្មក្នុងការផ្គត់ផ្គង់ការតភ្ជាប់ប្រព័ន្ធជាមួយប្រព័ន្ធនេះ

(ខ)-ការផ្តល់សេវាសំរាប់នាឡិកាស្ទង់ និង

(គ)-ការផ្គត់ផ្គង់អគ្គិសនីឱ្យអ្នកប្រើប្រាស់ ។

"កូដប្រព័ន្ធចែកចាយ" ជាក្បួនច្បាប់ដែលគ្របដណ្តប់លើទិដ្ឋភាពបច្ចេកទេសធំៗទាំងអស់ ដែលពាក់ព័ន្ធជាមួយការតភ្ជាប់ការដំណើរការ និងការប្រើប្រាស់ប្រព័ន្ធចែកចាយរបស់អគ្គិសនីកម្ពុជា ឬ ការដំណើរការខ្សែបណ្តាញ និងបរិក្ខាអគ្គិសនី ដែលបានតភ្ជាប់ជាមួយប្រព័ន្ធចែកចាយរបស់អគ្គិសនីកម្ពុជា ឬរបស់បុគ្គលណាមួយផ្សេងទៀត ដែលបានទទួលការអនុញ្ញាតឱ្យតភ្ជាប់ជាមួយប្រព័ន្ធរបស់អគ្គិសនីកម្ពុជា ។

"អាជ្ញាប័ណ្ណចែកចាយ" មានន័យថាអាជ្ញាប័ណ្ណចែកចាយដែលបានផ្តល់ក្នុងប្រការ១(គ) នៃផ្នែកទី១ ។

"ប្រព័ន្ធចែកចាយ " ចំពោះអគ្គិសនីកម្ពុជា មានន័យថា គឺជាខ្សែបណ្តាញអគ្គិសនីទាំងអស់របស់អគ្គិសនីកម្ពុជាក្នុងតំបន់ចែកចាយដែលបានអនុញ្ញាត(លើកលែងតែខ្សែបណ្តាញ ដែលជាផ្នែកមួយនៃប្រព័ន្ធបញ្ជូនរបស់អគ្គិសនីកម្ពុជា) និងខ្សែបណ្តាញអគ្គិសនីណាមួយផ្សេងទៀត ដែលអាជ្ញាធរអគ្គិសនីកម្ពុជាអាចបញ្ជាក់ថា គឺជាផ្នែកនៃប្រព័ន្ធចែកចាយរបស់អគ្គិសនីកម្ពុជា ព្រមទាំងនាឡិកាស្ទង់ និងបរិក្ខាអគ្គិសនីណាមួយរបស់អគ្គិសនីកម្ពុជា ដែលបានប្រើប្រាស់សំរាប់ចែកចាយអគ្គិសនី ដោយអគ្គិសនីកម្ពុជា ដោយឡែកចំពោះអ្នកចែកចាយដទៃណាមួយផ្សេងទៀតវាមានអត្ថន័យដូចគ្នាដូចមានចែងក្នុងអាជ្ញាប័ណ្ណដែលបានកាន់ដោយអ្នកកាន់អាជ្ញាប័ណ្ណចែកចាយនោះ ។

"អ្នកចែកចាយ" មានន័យថា គឺជាបុគ្គលណាមួយដែលបានកាន់អាជ្ញា ប័ណ្ណចែកចាយ ។

"អាជ្ញាធរអគ្គិសនីកម្ពុជា " មានន័យថា អាជ្ញាធរដែលបានបង្កើតឡើង ដោយច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/ ០២០១/០៣ ចុះថ្ងៃទី ២ ខែកុម្ភៈ ឆ្នាំ ២០០១ ។

"អគ្គិសនីកម្ពុជា " មានន័យថា ក្រុមហ៊ុនអគ្គិសនីកម្ពុជាដែលបានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ ជស/រកត/០៣៩៦ /១០ ចុះថ្ងៃទី ០៩ ខែមិនា ឆ្នាំ១៩៩៦ ។

"អាជីវកម្មផលិតកម្ម "មានន័យថា ការធ្វើអាជីវកម្ម (ប្រសិនបើមាន) របស់អគ្គិសនីកម្ពុជា (អ្នកកាន់អាជ្ញាប័ណ្ណផលិត) ឬសាខា របស់អគ្គិសនីកម្ពុជាណាមួយ ក្នុងការផលិតថាមពលអគ្គិសនី ។

"អាជ្ញាប័ណ្ណផលិតកម្ម" មានន័យថា គឺជាអាជ្ញាប័ណ្ណផលិតកម្មដែលបានផ្តល់ ក្នុងប្រការ១(ក) នៃផ្នែកទី១ ។

"ច្បាប់ " មានន័យថា ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី ២ ខែកុម្ភៈ ឆ្នាំ ២០០១ ។

"ឯកសារអាជ្ញាប័ណ្ណ " មានន័យថា គឺជាឯកសារនេះដែលមានពី ផ្នែកទី១ ដល់ ផ្នែកទី២ និងឧបសម្ព័ន្ធទី១ ដល់ឧបសម្ព័ន្ធទី៣ ។

”បរិក្ខានាឡិកាស្ទង់ ”រួមមាននាឡិកាស្ទង់ និងបរិក្ខាពាក់ព័ន្ធដទៃទៀត ដែលមានឥទ្ធិពលផ្ទាល់លើការដំណើរការនាឡិកាស្ទង់នោះ

”ការជូនដំណឹង ” មានន័យថា (ប្រសិនបើពុំមានការបញ្ជាក់ផ្សេង ទៀត) គឺការជូនដំណឹងជាលាយលក្ខណ៏អក្សរ ឬ ដោយមធ្យោបាយសមស្របណាមួយផ្សេងទៀត ។

”ការបញ្ជាក់ ” រួមមាន ការបដិសេធ ឬ ការសំណូមពរណាមួយ ដែលបានធ្វើជាលាយលក្ខណ៏អក្សរ ។

”អាជីវកម្មបញ្ជូន ” មានន័យថា គឺជាអាជីវកម្មដែលបានអនុញ្ញាតរបស់ អគ្គិសនីកម្ពុជា (អ្នកកាន់អាជ្ញាប័ណ្ណបញ្ជូន) ឬរបស់សាខាណាមួយរបស់អគ្គិសនីកម្ពុជា ក្នុងការធ្វើផែនការ ការអភិវឌ្ឍន៏ ការសាងសង់ និងការថែទាំជួសជុលប្រព័ន្ធបញ្ជូនរបស់អគ្គិសនីកម្ពុជា និងការដំណើរការប្រព័ន្ធនេះសំរាប់ការបញ្ជូនដោយអគ្គិសនីកម្ពុជា រួមទាំងអាជីវកម្មណាមួយ ក្នុងការតភ្ជាប់ប្រព័ន្ធជាមួយប្រព័ន្ធបញ្ជូនរបស់អគ្គិសនីកម្ពុជា ប៉ុន្តែមិនត្រូវរាប់បញ្ចូលអាជីវកម្មដទៃណាមួយផ្សេងទៀតរបស់អគ្គិសនីកម្ពុជា (ទោះជាអាជីវកម្មដាច់ដោយឡែក ឬមិនដោយឡែកក៏ដោយ) ឬរបស់សាខាណាមួយរបស់អគ្គិសនីកម្ពុជា ក្នុងការផ្តល់សេវាកម្មឱ្យ ឬជំនួសមុខឱ្យបុគ្គល ឬក្រុមហ៊ុនណាមួយឡើយ ។

”កូដប្រព័ន្ធបញ្ជូន ” មានន័យថា ច្បាប់ដែលគ្រប់គ្រងសកម្មភាពទាំងអស់ពាក់ព័ន្ធជាមួយការភ្ជាប់ការដំណើរការ និងការប្រើប្រាស់ប្រព័ន្ធបញ្ជូនរបស់អគ្គិសនីកម្ពុជា រួមទាំងការដំណើរការនៃខ្សែបណ្តាញនិងបរិក្ខាអគ្គិសនី ដែលតភ្ជាប់ជាមួយប្រព័ន្ធបញ្ជូនរបស់អគ្គិសនីកម្ពុជា ។

”អាជ្ញាប័ណ្ណបញ្ជូន ” មានន័យថា អាជ្ញាប័ណ្ណបញ្ជូនដែលបានផ្តល់ក្នុង ប្រការ ១(ខ) នៃផ្នែកទី ១ ។

”អ្នកកាន់អាជ្ញាប័ណ្ណបញ្ជូន ” មានន័យថា បុគ្គលដែលកាន់អាជ្ញាប័ណ្ណបញ្ជូន ។

”ប្រព័ន្ធបញ្ជូន ” របស់អគ្គិសនីកម្ពុជា ជាប្រព័ន្ធខ្សែបណ្តាញអគ្គិសនី ដែលមានប្រព័ន្ធខ្សែបណ្តាញតង់ស្យុងខ្ពស់របស់អគ្គិសនីកម្ពុជា និងខ្សែបណ្តាញអគ្គិសនីណាមួយផ្សេងទៀតដែលអាជ្ញាធរអគ្គិសនីកម្ពុជាអាចបញ្ជាក់ថា គឺជាផ្នែកមួយនៃប្រព័ន្ធបញ្ជូនរបស់អគ្គិសនីកម្ពុជាព្រម ទាំងបរិក្ខាអគ្គិសនី និងនាឡិកាស្ទង់របស់អគ្គិសនីកម្ពុជា ដែលបានប្រើប្រាស់ទាក់ទងជាមួយការបញ្ជូនរបស់អគ្គិសនីកម្ពុជាចំពោះអ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនណាមួយផ្សេងទៀតវាមាននិយមន័យដូចគ្នាដូចដែលមានចែងក្នុងអាជ្ញាប័ណ្ណ ដែលបានកាន់ដោយអ្នកកាន់អាជ្ញាប័ណ្ណបញ្ជូននោះ ។

# លក្ខខណ្ឌរបស់អាជ្ញាប័ណ្ណរួមសំរាប់អគ្គិសនីកម្ពុជា

## ជំពូកទី១

### ភារកិច្ចទូទៅរបស់អគ្គិសនីកម្ពុជា

**លក្ខខណ្ឌទី១: ភារកិច្ចគោរពច្បាប់ អនុក្រឹត្យ និងសេចក្តីសំរេចនានា**

១-អគ្គិសនីកម្ពុជាត្រូវគោរពតាមច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជាច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់។

២-អគ្គិសនីកម្ពុជាត្រូវគោរពតាមសេចក្តីសំរេចរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ក្នុងការដាក់វិធានបទបញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាព ដោយអនុលោមតាមអាណត្តិ និងលក្ខខណ្ឌនៃអាជ្ញាប័ណ្ណនេះ ។

៣-អគ្គិសនីកម្ពុជា ត្រូវគោរពតាមភារកិច្ចបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃ ទី២៤ ខែធ្នូ ឆ្នាំ ១៩៩៦ និងរាល់អនុក្រឹត្យនានាស្តីពីការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**លក្ខខណ្ឌទី២: ភារកិច្ចគោរពលក្ខខណ្ឌអាជីវកម្ម**

អគ្គិសនីកម្ពុជា ត្រូវគោរពតាមលក្ខខណ្ឌអាជីវកម្មដែលកំណត់ខាង ក្រោម :

១-អគ្គិសនីកម្ពុជាត្រូវដំណើរការ និងគ្រប់គ្រងសេវាកម្មអគ្គិសនី ដែលបានផ្តល់ដោយអាជ្ញាប័ណ្ណនេះឱ្យមានប្រសិទ្ធភាព គុណភាព និងតម្លាភាព ដោយអនុលោមតាមលក្ខខណ្ឌកំណត់ក្នុងអាជ្ញាប័ណ្ណនេះ និងបទប្បញ្ញត្តិដែលកំណត់ក្នុងវិធាននានារបស់អាជ្ញាធរអគ្គិសនីកម្ពុជា ។

២-អគ្គិសនីកម្ពុជាមិនត្រូវទទួលយកអាជីវកម្មបន្ថែមណាមួយទៀតរួមទាំងអាជីវកម្មផលិត បញ្ជូន ចែកចាយ ឬលក់ថាមពលដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរជាមុនពីអាជ្ញាធរអគ្គិសនីកម្ពុជាឡើយ ។

៣-អគ្គិសនីកម្ពុជា មិនត្រូវប្រើប្រាស់អចលនទ្រព្យនៃអាជីវកម្មរបស់អាជ្ញាប័ណ្ណនេះសំរាប់គោលបំណងអ្វីក្រៅពីការផលិត ការបញ្ជូន ការចែកចាយអគ្គិសនី ដូចដែលបានកំណត់ក្នុងឯកសារនេះ ដោយពុំមានការអនុម័តជាមុនពីអាជ្ញាធរអគ្គិសនីកម្ពុជាឡើយ ។

៤-អគ្គិសនីកម្ពុជាពុំត្រូវចុះកិច្ចព្រមព្រៀងជាមួយភាគីទី៣ដើម្បីទិញអគ្គិសនី ដោយគ្មានការអនុម័តជាមុនពីអាជ្ញាធរអគ្គិសនីកម្ពុជាឡើយ ។

៥-កិច្ចព្រមព្រៀងណាមួយពាក់ព័ន្ធជាមួយកិច្ចការដែលបានអធិប្បាយក្នុងវាក្យខ័ណ្ឌទី២ ទី៣ និងទី៤ ខាងលើបើពុំមានការឯកភាពជាលាយលក្ខណ៍អក្សរជាមុនពីអាជ្ញាធរអគ្គិសនីកម្ពុជាទេត្រូវចាត់ទុកថាជាមោឃៈ និងត្រូវទុកជាការរំលោភលើលក្ខខណ្ឌនៃអាជ្ញាប័ណ្ណនេះ ។

៦-វិវាទឬជំម្លោះណារវាងអគ្គិសនីកម្ពុជា និងភាគីទី៣ ដែលទាក់ទងនឹងកិច្ចព្រមព្រៀងណាមួយក្នុងការទិញអគ្គិសនីជាមួយភាគីទី៣ត្រូវដោះស្រាយអនុលោមតាមលក្ខខណ្ឌក្នុងកិច្ចព្រមព្រៀងជាមួយភាគីនោះ ។

**ល័ក្ខខ័ណ្ឌទី៣:  កាតព្វកិច្ចធ្វើរបាយការណ៍ហិរញ្ញវត្ថុ  របស់អគ្គិសនីកម្ពុជា**

១- ឆ្នាំការិយបរិច្ឆេទនៃអគ្គិសនីកម្ពុជា ត្រូវចាប់គិតពីថ្ងៃទី០១ ខែមករា រហូតដល់ថ្ងៃទី៣១ ខែធ្នូ រៀងរាល់ឆ្នាំ ។

២- អគ្គិសនីកម្ពុជាត្រូវរៀបចំកត់ត្រាគណនី និងធ្វើរបាយការណ៍គណនី ដែលអាចបែងចែកគណនីដោយឡែកសំរាប់អាជីវកម្មដោយឡែកនីមួយៗ និងអាចបង្ហាញកិច្ចការហិរញ្ញវត្ថុនៃអាជីវកម្មដោយឡែកនីមួយៗនេះ។

"អាជីវកម្មដោយឡែក" មានន័យថា អាជីវកម្មផលិត អាជីវកម្មបញ្ជូន និងអាជីវកម្មចែកចាយ ។

៣-អគ្គិសនីកម្ពុជាត្រូវរៀបចំ និងធ្វើឱ្យអាជ្ញាធរអគ្គិសនីកម្ពុជានូវរបាយការណ៍គណនីសរុបរបស់សាខានីមួយៗ និងរបស់អគ្គិសនីកម្ពុជាទាំងមូល ដែលបានធ្វើសវនកម្មរួចមិនលើសពី ៦ខែ បន្ទាប់ពីពេលបញ្ចប់ឆ្នាំការិយបរិច្ឆេទ។

**ល័ក្ខខ័ណ្ឌទី៤:  កាតព្វកិច្ចក្នុងការទិញថាមពលអគ្គិសនី**

១-អគ្គិសនីកម្ពុជាត្រូវទិញអគ្គិសនីតាមថ្លៃសុក្រឹតមួយដែលអាចទទួលបានតាមការពិនិត្យប្រភពដែលមាននៅពេលបច្ចុប្បន្ន និងទៅអនាគត ដោយឆ្លងកាត់តាមការជ្រើសរើស និងវាយតំលៃលើគំរោងការផលិតកម្ម។ អគ្គិសនីកម្ពុជាត្រូវអនុវត្តតាមឯកសារណែនាំនិងនីតិវិធី ដែលបានអនុម័តដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងអាជ្ញាធរអគ្គិសនីកម្ពុជាក្នុងការជ្រើសរើស និងវាយតម្លៃការស្នើសុំក្នុងគំរោងផលិតកម្ម ។ ក្នុងនោះត្រូវបញ្ចូលនូវការដំណើរការការដេញ ថ្លៃជា២វគ្គសំរាប់ទីតាំង ដែលមានលទ្ធភាពផលិតនីមួយៗ ។ ការសិក្សាពីសមិទ្ធិលទ្ធភាពលំអិតត្រូវតែមានមុនពេលដំណើរការដេញថ្លៃចាប់ផ្តើម ។ ឯកសារដាក់ដេញថ្លៃត្រូវតែមានបញ្ជាក់ថាគំរោងប្រើប្រាស់ទីតាំងណា ប្រេងឥន្ទនៈ និងបច្ចេកវិទ្យាណាណានិងត្រូវតែអនុវត្តតាមកម្មវិធីដែលបានផ្សព្វផ្សាយសំរាប់ការជ្រើសរើស និងការអនុម័តគំរោង ។ ត្រូវតែមានការធានាឱ្យច្បាស់លាស់ថាគំរោងណាដែលមិនអាចផ្តល់ហិរញ្ញប្បទានបានតាមពេលកំណត់ត្រូវតែអស់សុពលភាព ។

២-ក្នុងការអនុវត្តនីកាតព្វកិច្ចតាមវាក្យខ័ណ្ឌទី១ អគ្គិសនីកម្ពុជាត្រូវពិនិត្យមើលបន្ថែមលើកត្តាណាមួយដែលមានឥទ្ធិពលលើលទ្ធភាពរបស់ខ្លួន និងរបស់សាខាឬអង្គភាពក្រោមវិវាទនៃអគ្គិសនីកម្ពុជាដើម្បីអនុវត្តកាតព្វកិច្ចរបស់គេតាមល័ក្ខខ័ណ្ឌនេះក្នុងពេលអនាគត ដូចជាមូលនិធិបំរុងបំណុល និងការបំបែកប្រភពនៃប្រេងឥន្ទនៈសំរាប់ផលិតកម្មផ្ទាល់ និងលទ្ធភាពអគ្គិសនី ដែលមានសំរាប់ទិញនៅពេលអនាគត ។

៣-ក្នុងគោលដៅនៃវាក្យខ័ណ្ឌទី១ កិច្ចព្រមព្រៀងណាមួយដែលដាក់ល័ក្ខខ័ណ្ឌឱ្យអគ្គិសនីកម្ពុជា ត្រូវទូទាត់ឱ្យភាគីមួយទៀតនៃកិច្ចព្រមព្រៀងក្នុងករណី ដែលអគ្គិសនីកម្ពុជាមិនបានទិញ ឬ ទទួលយកអគ្គិសនី (ឬបរិមាណអគ្គិសនីអប្បបរមាមួយ) ក្រោមកិច្ចព្រមព្រៀងត្រូវចាត់ទុកថាជាកិច្ចព្រមព្រៀងមួយ ដែលនៅក្នុងនោះអគ្គិសនីកម្ពុជាមានកាតព្វកិច្ចទទួលយកការទិញអគ្គិសនីដាច់ខាត ឯបរិមាណអគ្គិសនីណាមួយ ដែលកំណត់ថាត្រូវទិញដោយអគ្គិសនីកម្ពុជាអនុលោមតាមកិច្ចព្រមព្រៀងត្រូវចាត់ទុកថាបានទិញក្នុងការអនុវត្តនីកាតព្វកិច្ចទទួលយកការទិញអគ្គិសនីដាច់ខាត ប្រសិនបើអគ្គិសនីកម្ពុជាមានកាតព្វកិច្ចត្រូវទូទាត់ទៅឱ្យភាគីមួយទៀតនៃកិច្ចព្រមព្រៀងទោះបីជា មិនបានទទួលយកបរិមាណអគ្គិសនីនោះក៏ដោយ ។

**ល័ក្ខខ័ណ្ឌទី៥:  កាតព្វកិច្ចក្នុងការការពារសុខភាព  និងសុវត្ថិភាពនៃអ្នកធ្វើការ**

១-អគ្គិសនីកម្ពុជាត្រូវពិគ្រោះយោបល់ជាមួយតំណាងបុគ្គលិកនិងកម្មកររបស់ខ្លួនដើម្បីបង្កើតឱ្យមានយន្តការ ឬវេទិកាជាប្រចាំមួយ ដើម្បីរួមគ្នាគិតគូរអំពីបញ្ហារួមពាក់ព័ន្ធនឹងបញ្ហាសុខភាព និងសុវត្ថិភាពរបស់បុគ្គលិកកម្មករ ។

**ល័ក្ខខ័ណ្ឌទី៦ : ភាតព្វកិច្ចផ្តល់ពត៌មានដល់អាជ្ញាធរអគ្គិសនីកម្ពុជា**

១-អគ្គិសនីកម្ពុជាត្រូវផ្តល់ឱ្យអាជ្ញាធរអគ្គិសនីកម្ពុជា នូវបណ្តាពត៌មានទាំងឡាយ ដែលអាជ្ញាធរទាមទារជាបន្តបន្ទាប់តាមបែបបទ និងទំរង់កំណត់ដោយអាជ្ញាធរ ដើម្បីអាចឱ្យអាជ្ញាធរផ្ទៀងផ្ទាត់មើលការអនុវត្តន៍របស់អគ្គិសនីកម្ពុជាតាមល័ក្ខខ័ណ្ឌនៃអាជ្ញាប័ណ្ណរួមនេះ និងតាមការកំណត់នៃច្បាប់ និងបទប្បញ្ញត្តិផ្សេងៗទៀត ។

២-ដោយមិនគិតពីភាពទូទៅនៃវាក្យខ័ណ្ឌទី១ អាជ្ញាធរអគ្គិសនីកម្ពុជាអាចទាមទារឱ្យអគ្គិសនីកម្ពុជាផ្តល់នូវពត៌មានណាមួយឱ្យមានលក្ខណៈលំអិតខ្លាំងជាង ឬខុសពីការផ្តល់ពត៌មានធម្មតាដល់អាជ្ញាធរអគ្គិសនីកម្ពុជា ។

**ល័ក្ខខ័ណ្ឌទី៧ : ភាតព្វកិច្ចបង់កំរៃអាជ្ញាប័ណ្ណ**

១-អគ្គិសនីកម្ពុជាត្រូវបង់ឱ្យអាជ្ញាធរអគ្គិសនីកម្ពុជានូវកំរៃអាជ្ញាប័ណ្ណ តាមចំនួននិងតាមពេលវេលា ដែលបានកំណត់ក្នុងល័ក្ខខ័ណ្ឌនេះ។

២-ចាប់ពីថ្ងៃចូលជាធរមានរហូតដល់ថ្ងៃបញ្ចប់អាណត្តិនៃអាជ្ញាប័ណ្ណនេះ អគ្គិសនីកម្ពុជាត្រូវបង់ឱ្យអាជ្ញាធរអគ្គិសនីកម្ពុជានូវ "**កំរៃអាជ្ញាប័ណ្ណសរុបប្រចាំខែ**" នៃសេវាកម្មគ្រប់ប្រភេទ និងទីតាំងសេវាកម្មគ្រប់កន្លែងដែលបានអនុញ្ញាតដោយអាជ្ញាប័ណ្ណនេះតាមប្រភេទសេវាកម្ម អាត្រាកំរៃអាជ្ញាប័ណ្ណ និងរូបមន្តគណនាកំរៃអាជ្ញាប័ណ្ណដែលត្រូវកំណត់ដោយអាជ្ញាធរអគ្គិសនីកម្ពុជាសំរាប់ឆ្នាំការិយបរិច្ឆេទនីមួយៗ អនុលោមតាមមាត្រា២៧ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣នៃអនុក្រឹត្យស្តីពីការកំណត់កំរិតអតិបរមានៃកំរៃអាជ្ញាប័ណ្ណសំរាប់អនុវត្តចំពោះអ្នកធ្វើសេវាកម្មអគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

៣-វិក័យប័ត្រនៃកំរៃអាជ្ញាប័ណ្ណប្រចាំខែត្រូវចាត់ទុកថាជំពាក់ និងត្រូវបង់ក្នុងរយៈពេល១៤ថ្ងៃបន្ទាប់ពីថ្ងៃ ដែលអគ្គិសនីកម្ពុជាបានទទួលវិក័យប័ត្រ ។

## ជំពូកទី២

## ល័ក្ខខ័ណ្ឌសំរាប់អាជ្ញាប័ណ្ណផលិតកម្ម

**ល័ក្ខខ័ណ្ឌទី១: ល័ក្ខខ័ណ្ឌចំពោះមធ្យោបាយផលិតកម្ម**

១-ក្នុងក្របខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ បើសិនជា អគ្គិសនីកម្ពុជាមានបំណងបន្ថែមមធ្យោបាយផលិតកម្មថ្មីថែមទៀតពេលនោះគេត្រូវស្នើសុំ អាជ្ញាប័ណ្ណផលិតកម្ម សំរាប់មធ្យោបាយផលិតកម្មថ្មីនីមួយៗ ។

២-មធ្យោបាយផលិតកម្មដែលមានស្រាប់របស់អគ្គិសនីកម្ពុជា មានបញ្ជាក់ក្នុងឧបសម្ព័ន្ធទី១ ។

**ល័ក្ខខ័ណ្ឌទី២: ល័ក្ខខ័ណ្ឌចំពោះកិច្ចដំណើរការផលិតកម្ម**

១-អគ្គិសនីកម្ពុជាត្រូវធ្វើផែនការនិងអភិវឌ្ឍផ្នែកនីមួយៗ នៃប្រព័ន្ធផ្ទៃក្នុងរបស់រោងចក្រផលិតកម្មរបស់ខ្លួននីមួយៗ ដោយអនុលោមតាមស្តង់ដាមួយ ដែលអាចឱ្យកិច្ចដំណើរការផលិតកម្មមានប្រសិទ្ធភាព ស្ថេរភាព និង គុណភាព។ "ប្រព័ន្ធផ្ទៃក្នុង " មានន័យថា ខ្សែបណ្តាញ បរិក្ខាអគ្គិសនីផ្ទៃក្នុង និងនាឡិកាស្ទង់របស់អ្នកកាន់អាជ្ញាប័ណ្ណដែលបានប្រើប្រាស់សំរាប់ការផលិតអគ្គិសនី ។

២-អគ្គិសនីកម្ពុជា ត្រូវសហការជាមួយផលិតករអគ្គិសនីឯករាជដទៃទៀត ដែលខ្លួនបានចុះកិច្ចព្រមព្រៀងទិញអគ្គិសនីមួយ ដើម្បីរៀបចំកម្មវិធីបញ្ឈប់ដំណើរការផលិតតាមផែនការរបស់រោងចក្រផលិតកម្មនីមួយៗក្នុងឆ្នាំការិយបរិច្ឆេទ ។ កម្មវិធីនេះត្រូវដាក់ស្នើសុំសេចក្តីសំរេចពីអាជ្ញាធរអគ្គិសនីកម្ពុជា ។ អាជ្ញាធរអគ្គិសនីកម្ពុជា

(បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយគ្រប់ភាគី) អាចកែសំរួលឬអនុម័តផែនការបញ្ឈប់ម៉ាស៊ីនខាងលើឱ្យបានមុនពេលចាប់ផ្តើមឆ្នាំការិយបរិច្ឆេទ ។

៣-អគ្គិសនីកម្ពុជាត្រូវរៀបចំ និងជូនពត៌មានឱ្យអាជ្ញាធរអគ្គិសនីកម្ពុជាបានដឹងនូវផែនការសកម្មភាព ដែលអគ្គិសនីកម្ពុជាត្រូវអនុវត្តដើម្បីឱ្យកិច្ច ដំណើរការផលិតកម្មមានប្រសិទ្ធភាព ស្ថេរភាព និងគុណភាព ។

**ល័ក្ខខ័ណ្ឌទី៣: ការគោរពកូដប្រព័ន្ធបញ្ជូន និងកូដប្រព័ន្ធចែកចាយ**

១-អគ្គិសនីកម្ពុជាត្រូវគោរពតាមបញ្ញត្តិទាំងឡាយនៃកូដប្រព័ន្ធបញ្ជូន និងកូដប្រព័ន្ធចែកចាយ ដែលបានអនុម័តរួច។

២-អាជ្ញាធរអគ្គិសនីកម្ពុជា (បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយអគ្គិសនីកម្ពុជានិងអ្នកកាន់អាជ្ញាប័ណ្ណបញ្ជូន ឬ ចែកចាយដទៃទៀត ដែលអាជ្ញាធរ យល់ថាសមស្រប) អាចចេញលិខិតណែនាំបន្ធូរបន្ថយកាតព្វកិច្ចរបស់អគ្គិសនីកម្ពុជាក្នុងវាក្យខ័ណ្ឌទី១ ចំពោះផ្នែកខ្លះនៃកូដប្រព័ន្ធបញ្ជូន និង កូដប្រព័ន្ធចែកចាយ ។

## ជំពូកទី៣

**ល័ក្ខខ័ណ្ឌសំរាប់អាជ្ញាប័ណ្ណបញ្ជូន**

**ល័ក្ខខ័ណ្ឌទី១: ល័ក្ខខ័ណ្ឌរៀបចំកូដប្រព័ន្ធបញ្ជូន**

១-អគ្គិសនីកម្ពុជាត្រូវរៀបចំកូដប្រព័ន្ធបញ្ជូនរបស់ខ្លួន និងផ្ញើមកអាជ្ញាធរអគ្គិសនីកម្ពុជាដើម្បីស្នើសុំការអនុម័ត ។ បន្ទាប់ពីការអនុម័តរបស់អាជ្ញាធរ កូដប្រព័ន្ធបញ្ជូននេះត្រូវចូលជាធរមានរួច អគ្គិសនីកម្ពុជាត្រូវតែអនុវត្ត និងគោរពតាមកូដប្រព័ន្ធបញ្ជូននេះ ។

២-អគ្គិសនីកម្ពុជាត្រូវពិនិត្យឡើងវិញជាប្រចាំ (រួមទាំងសំណូមពររបស់ អាជ្ញាធរអគ្គិសនីកម្ពុជា) នូវកូដប្រព័ន្ធបញ្ជូន និងការអនុវត្តន៍របស់វា ។

៣-ការកែសំរួលកូដប្រព័ន្ធបញ្ជូន ដែលសំណូមពរដោយអគ្គិសនីកម្ពុជាត្រូវទាមទារការអនុម័តពីអាជ្ញាធរអគ្គិសនីកម្ពុជា ។

៤-អាជ្ញាធរអគ្គិសនីកម្ពុជា (បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយអគ្គិសនីកម្ពុជា) អាចចេញលិខិតណែនាំបន្ធូរបន្ថយកាតព្វកិច្ចរបស់អគ្គិសនីកម្ពុជាក្នុងក្របខ័ណ្ឌកូដប្រព័ន្ធបញ្ជូនលើផ្នែកខ្លះនៃប្រព័ន្ធបញ្ជូនរបស់អគ្គិសនីកម្ពុជាតាមទំហំណាមួយ ដែលត្រូវបានកំណត់ក្នុងលិខិតណែនាំ។

**ល័ក្ខខ័ណ្ឌទី២: ស្តង់ដាសន្តិសុខប្រព័ន្ធបញ្ជូន និងគុណភាពនៃសេវា**

១-អគ្គិសនីកម្ពុជាត្រូវ :

(ក)-ធ្វើផែនការនិងអភិវឌ្ឍន៍ប្រព័ន្ធបញ្ជូនរបស់ខ្លួនដោយអនុលោមតាមកម្មវិធីវិនិយោគផែនការអភិវឌ្ឍន៍របស់ខ្លួន កូដប្រព័ន្ធបញ្ជូន និងស្តង់ដាដំណើរការផ្សេងៗទៀត និង

(ខ)-ដំណើរការប្រព័ន្ធបញ្ជូនរបស់ខ្លួនស្របតាមឯកសារណែនាំការគ្រប់គ្រងស្តង់ដាប្រតិបត្តិ នៃការផ្គត់ផ្គង់ប្រកបដោយស្ថេរភាព កូដប្រព័ន្ធបញ្ជូន និងស្តង់ដាដំណើរការផ្សេងៗទៀត ។

២-អគ្គិសនីកម្ពុជាត្រូវរៀបចំ និងដាក់ស្នើសុំអាជ្ញាធរអគ្គិសនីកម្ពុជា ដើម្បីអនុម័តនូវឯកសារ ដែលកំណត់ពីគោលការណ៍ ដែលអគ្គិសនីកម្ពុជាត្រូវអនុវត្ត ដើម្បីថែរក្សាប្រព័ន្ធបញ្ជូនឱ្យមានស្ថេរភាព មានលទ្ធភាព និងគុណភាពនៃសេវា ។

៣-អគ្គិសនីកម្ពុជាក្នុងរយៈពេល ៣ខែ ក្រោយបញ្ចប់ឆ្នាំការិយបរិច្ឆេទនីមួយៗ ត្រូវផ្តល់ឱ្យអាជ្ញាធរអគ្គិសនីកម្ពុជានូវរបាយការណ៍ស្តីពីពត៌មានលំអិត នៃការអនុវត្តន៍របស់អគ្គិសនីកម្ពុជាក្នុងឆ្នាំការិយបរិច្ឆេទ ពាក់ព័ន្ធនឹងគោលការណ៍ ដែលបានអធិប្បាយក្នុងវាក្យខ័ណ្ឌទី២ ។

៤-អាជ្ញាធរអគ្គិសនីកម្ពុជា (បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយអគ្គិសនីកម្ពុជា)អាចចេញលិខិតណែនាំបន្ធូរបន្ថយកាតព្វកិច្ចរបស់អគ្គិសនីកម្ពុជា ក្នុងក្របខ័ណ្ឌនៃវាក្យខ័ណ្ឌទី១ ចំពោះផ្នែកណាមួយនៃប្រព័ន្ធបញ្ជូនរបស់អគ្គិសនីកម្ពុជាតាមទំហំដែលកំណត់ក្នុងលិខិតណែនាំ ។

៥-អគ្គិសនីកម្ពុជាត្រូវផ្តល់ និងធ្វើឱ្យអ្នកស្នើសុំណាមួយ នូវច្បាប់ចម្លងនៃឯកសារខាងលើ (ដែលបានកែសំរួលជាបន្តបន្ទាប់) ដោយមានល័ក្ខខ័ណ្ឌឱ្យអគ្គិសនីកម្ពុជាអាចគិតប្រាក់លើឯកសារ ដែលបានផ្តល់ ឬធ្វើនោះតាមថ្លៃមួយមិនលើសពីចំនួន ដែលកំណត់ជាបន្តបន្ទាប់ក្នុងក្របខ័ណ្ឌនៃល័ក្ខខ័ណ្ឌនេះក្នុងលិខិតណែនាំ ដែលចេញដោយអាជ្ញាធរអគ្គិសនីកម្ពុជា។

**ល័ក្ខខ័ណ្ឌទី៣ : ល័ក្ខខ័ណ្ឌគោរពកូដប្រព័ន្ធចែកចាយ**

១-អគ្គិសនីកម្ពុជា ត្រូវគោរពតាមបញ្ញត្តិទាំងឡាយនៃកូដប្រព័ន្ធចែកចាយរបស់ខ្លួន ព្រមទាំងកូដប្រព័ន្ធចែកចាយរបស់អ្នកចែកចាយផ្សេងៗទៀត ដែលមានទំនាក់ទំនងក្នុងអាជីវកម្ម ដែលបានទទួលការអនុញ្ញាតរបស់អគ្គិសនីកម្ពុជា ។

២-អាជ្ញាធរអគ្គិសនីកម្ពុជា (បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយអគ្គិសនីកម្ពុជា និងអ្នកចែកចាយផ្សេងៗទៀតដែលអាជ្ញាធរអគ្គិសនីកម្ពុជាយល់ថាសមស្រប)អាចចេញលិខិតណែនាំបន្ធូរបន្ថយកាតព្វកិច្ចរបស់អគ្គិសនីកម្ពុជាតាមវាក្យខ័ណ្ឌទី១ ទាក់ទងនឹងផ្នែកណាមួយនៃកូដប្រព័ន្ធចែកចាយរបស់អគ្គិសនីកម្ពុជា ឬកូដប្រព័ន្ធចែកចាយរបស់អ្នកចែកចាយផ្សេងទៀត និងក្នុងករណីនីមួយៗតាមទំហំមួយ ដែលកំណត់ក្នុងលិខិតណែនាំ ។

**ល័ក្ខខ័ណ្ឌទី៤: ការបោះបង់ចោលអចលនទ្រព្យអាជីវកម្ម**

១-អគ្គិសនីកម្ពុជាមិនត្រូវបោះបង់ចោល ឬ បដិសេធចោលការគ្រប់គ្រងដំណើរការលើអចលនទ្រព្យអាជីវកម្មណាមួយ មុនពេលមានការឯកភាព ពីអាជ្ញាធរអគ្គិសនីកម្ពុជាឡើយ ។"អចលនទ្រព្យអាជីវកម្ម" មានន័យថាគឺជាអចលនទ្រព្យណាមួយដែលពេលនោះជាផ្នែកមួយនៃប្រព័ន្ធបញ្ជូនរបស់អគ្គិសនីកម្ពុជាមជ្ឈមណ្ឌលបញ្ជាណាមួយ ដែលប្រើប្រាស់ជាមួយប្រព័ន្ធបញ្ជូននោះ និងសិទ្ធិ ឬង់កម្មសិទ្ធិ ឬ អត្ថប្រយោជន៍ណាមួយលើដីដែលអចលនទ្រព្យរៀបរាប់ស្ថិតនៅ ។

២-អគ្គិសនីកម្ពុជា ត្រូវផ្តល់ឱ្យអាជ្ញាធរនូវសំណើជាលាយលក្ខណ៍អក្សរស្តីពីគោលបំណងរបស់គេក្នុងការបោះបង់ចោល ឬ បដិសេធចោលការគ្រប់គ្រងដំណើរការលើអចលនទ្រព្យអាជីវកម្មណាមួយ ដោយភ្ជាប់ជាមួយពត៌មានបន្ថែមផ្សេងៗទៀតតាមដែលអាជ្ញាធរស្នើសុំពាក់ព័ន្ធជា មួយនឹងអចលនទ្រព្យនោះ ឬកាលៈទេសៈនៃការលះបង់ ឬបដិសេធចោលការគ្រប់គ្រងនេះ ឬ គោលបំណងនៃបុគ្គលណាមួយ ដែលចង់ទទួលយក ឬទទួលគ្រប់គ្រងដំណើរការលើអចលនទ្រព្យនោះ ។

៣-អាជ្ញាធរអគ្គិសនីកម្ពុជា (បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយអគ្គិសនីកម្ពុជា) អាចយល់ព្រម ឬ មិនយល់ព្រមនូវសំណើនេះ ។

**ល័ក្ខខ័ណ្ឌទី៥: ការកំរិតព្រំដែននៃការប្រើប្រាស់ពត៌មានមួយចំនួននៃអាជីវកម្ម បញ្ជូនអគ្គិសនី និងឯករាជ្យភាពរបស់វា**

១-អគ្គិសនីកម្ពុជាត្រូវបង្កើត និងបន្ទាប់មកត្រូវរក្សានូវឯករាជ្យភាពពេញលេញនៃការគ្រប់គ្រង និងការដំណើរការ អាជីវកម្មបញ្ជូនអគ្គិសនីដោយ ឡែកពីអាជីវកម្មដទៃទៀតរបស់អគ្គិសនីកម្ពុជា ។

២-អគ្គិសនីកម្ពុជាត្រូវរៀបចំឱ្យអ្នកគ្រប់គ្រងអាជីវកម្មបញ្ជូនអគ្គិសនី មានសិទ្ធិបំពេញនូវភារកិច្ច និងការទទួល ខុសត្រូវរបស់គេស្របតាមវាក្យខ័ណ្ឌទី១ ។

៣-ពត៌មានណាមួយដែលទាក់ទងជាមួយ ឬចេញមកពីការគ្រប់គ្រង ឬការដំណើរការអាជីវកម្មបញ្ជូនអគ្គិសនី តាមគោលបំណងនៃល័ក្ខខ័ណ្ឌ នេះ ត្រូវរក្សាវាដូចជាពត៌មានសំងាត់ ។

៤-អគ្គិសនីកម្ពុជាអាចបើកបង្ហាញ ឬអនុញ្ញាតឱ្យដឹងនូវពត៌មានសំងាត់តែក្នុងករណីដែលខ្លួនយល់ថាចាំបាច់ប៉ុណ្ណោះ

**ល័ក្ខខ័ណ្ឌទី៦: ល័ក្ខខ័ណ្ឌបញ្ឈប់ដំណើរការប្រព័ន្ធបញ្ជូន**

១-អគ្គិសនីកម្ពុជាត្រូវរៀបចំនិងដាក់ឱ្យអាជ្ញាធរអគ្គិសនីកម្ពុជា នូវកម្មវិធីបញ្ឈប់ដំណើរការតាមផែនការរបស់ប្រព័ន្ធ បញ្ជូនរបស់ខ្លួនក្នុងឆ្នាំការិយបរិច្ឆេទនីមួយៗ ។

២-អាជ្ញាធរអគ្គិសនីកម្ពុជា (បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយអគ្គិសនីកម្ពុជា) អាចកែសំរួលឬអនុម័តកម្មវិធី បញ្ឈប់ដំណើរការតាមផែនការនេះ មុនពេលចាប់ផ្តើមឆ្នាំការិយបរិច្ឆេទ ។

៣-អគ្គិសនីកម្ពុជា ត្រូវបញ្ជាក់ប្រាប់អាជ្ញាធរអគ្គិសនីកម្ពុជាជាលាយលក្ខណ៍អក្សរក្នុងករណីអគ្គិសនីកម្ពុជាមិនយល់ ព្រមនឹងកម្មវិធីបញ្ឈប់ដំណើរការតាមផែនការ ដែលបានអនុម័តដោយអាជ្ញាធរចំពោះប្រព័ន្ធបញ្ជូនរបស់ខ្លួនក្នុង ឆ្នាំការិយបរិច្ឆេទណាមួយមុនពេលចាប់ផ្តើមឆ្នាំការិយបរិច្ឆេទនោះ

## ជំពូកទី៤

**ល័ក្ខខ័ណ្ឌសំរាប់អាជ្ញាប័ណ្ណចែកចាយ**

**ល័ក្ខខ័ណ្ឌទី១: ស្តង់ដាការពារមិនឱ្យខ្វះខាតផលិតកម្មអគ្គិសនី**

១-អគ្គិសនីកម្ពុជាត្រូវរៀបចំឱ្យមានប្រភពអគ្គិសនីគ្រប់គ្រាន់មួយសំរាប់ផ្គត់ផ្គង់ឱ្យអតិថិជនរបស់ខ្លួន ។ អគ្គិសនីកម្ពុជាត្រូវធានានូវល័ក្ខខ័ណ្ឌ ដូចខាងក្រោម :

(ក)-មិនត្រូវមានការកាត់ផ្តាច់លើសពីរយៈពេលស្តង់ដា ដែលបាន អនុម័តដោយអាជ្ញាធរអគ្គិសនីកម្ពុជា និង

(ខ)-តង់ស្យុង និងប្រេកង់អគ្គិសនី មិនត្រូវទាបជាងព្រំដែនដំណើរការជាធម្មតា ដែលអនុម័តដោយអាជ្ញាធរ អគ្គិសនីកម្ពុជាឡើយ ។

**ល័ក្ខខ័ណ្ឌទី២ : ស្តង់ដាធ្វើផែនការប្រព័ន្ធចែកចាយ និងគុណភាពនៃសេវា**

១-ការធ្វើផែនការ និងការអភិវឌ្ឍនីប្រព័ន្ធចែកចាយរបស់អគ្គិសនីកម្ពុជា ត្រូវអនុវត្តតាមស្តង់ដាមួយដែលចេញ ដោយក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ឬតាមស្តង់ដាដទៃទៀត ដែលអគ្គិសនីកម្ពុជាអាចរក្សាបាននូវ សន្តិសុខ លទ្ធភាព និងគុណភាពនៃសេវារបស់ប្រព័ន្ធចែកចាយ ។

២-អ្នកកាន់អាជ្ញាប័ណ្ណត្រូវរៀបចំ និងដាក់ជូនអាជ្ញាធរអគ្គិសនីកម្ពុជា ពិនិត្យពីលក្ខណៈវិនិច្ឆ័យសំរាប់វាស់វែង គុណភាពនៃការអនុវត្តនីរបស់ខ្លួនតាមវាក្យខ័ណ្ឌទី១ខាងលើ ។

**លក្ខខណ្ឌទី៣ : សន្តិសុខ និងសុវត្ថិភាពនៃការផ្គត់ផ្គង់**

១-អគ្គិសនីកម្ពុជាត្រូវបង្កើត និងដំណើរការនូវសេវាផ្តល់ពត៌មានមួយសំរាប់ផ្តល់ពត៌មានឱ្យបុគ្គលណាមួយ ដែលចង់ដឹងពីពត៌មាន ការណែនាំ ឬការផ្តល់យោបល់ពីបញ្ហាណាមួយ ឬ ឧប្បត្តិហេតុណាមួយដែល :

(ក)-ជាមូលហេតុនៃគ្រោះថ្នាក់ឬទាមទារការយកចិត្តទុកដាក់បន្ទាន់ ឬជាបញ្ហាដែលប្រហែលអាចជាមូលហេតុនៃគ្រោះថ្នាក់ ឬទាមទារការយកចិត្តទុកដាក់បន្ទាន់ទាក់ទងនឹងការផ្គត់ផ្គង់ ឬការចែកចាយអគ្គិសនីក្នុងតំបន់ អនុញ្ញាតរបស់អគ្គិសនីកម្ពុជា ឬ

(ខ)-មានឥទ្ធិពល ឬជឿជាក់ថាមានឥទ្ធិពលលើការថែទាំសន្តិសុខ លទ្ធភាព និងគុណភាពនៃសេវាប្រព័ន្ធចែកចាយរបស់អគ្គិសនីកម្ពុជា។

២-សេវាដែលបានបង្កើតឡើងដោយអគ្គិសនីកម្ពុជា អនុលោមតាមវាក្យខ័ណ្ឌទី១ខាងលើត្រូវ :

(ក)-ផ្តល់ឱ្យអ្នកប្រើប្រាស់ដោយពុំគិតកំរៃតាមចំណុចដែលត្រូវការប្រើប្រាស់

(ខ)-ធានាថា របាយការណ៍ និងសំណួរទាំងឡាយត្រូវដំណើរការយ៉ាងរហ័ស និងប្រកបដោយប្រសិទ្ធភាពខ្ពស់ទោះជាតាមទូរស័ព្ទ ឬជាលាយលក្ខណ៍អក្សរក៏ដោយ និង

(គ)-អាចទទួលរបាយការណ៍ និងការសាកសួរតាមទូរស័ព្ទបានគ្រប់ពេលវេលា ជារៀងរាល់ថ្ងៃនៃឆ្នាំនីមួយៗ

៣-អគ្គិសនីកម្ពុជាត្រូវរៀបចំនិងធ្វើយ៉ាងណាឱ្យអតិថិជនរបស់ខ្លួនបានទទួលនូវពត៌មានអំពីអាសយដ្ឋាន និងលេខទូរស័ព្ទនៃសេវា ដែលបានបង្កើតឡើង អនុលោមតាមវាក្យខ័ណ្ឌទី១ ដើម្បីឱ្យគេអាចទាក់ទងបាន ។

៤-អគ្គិសនីកម្ពុជាត្រូវបំពេញនូវភារកិច្ចកំណត់ក្នុងវាក្យខ័ណ្ឌទី៣ ដោយផ្តល់ឱ្យអតិថិជនរបស់ខ្លួននីមួយៗនូវបណ្តាពត៌មានដែលគេសាកសួរ ។

៥-អគ្គិសនីកម្ពុជាត្រូវជូនពត៌មានដល់អតិថិជនរបស់ខ្លួននូវការផ្លាស់ប្តូរអាសយដ្ឋាន និងលេខទូរស័ព្ទនៃសេវា ដែលបានបង្កើតឡើងអនុលោមតាមវាក្យខ័ណ្ឌទី១ នោះឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបានមុនពេលការផ្លាស់ប្តូរនេះបានចូលជាធរមាន ។

**លក្ខខណ្ឌទី៤ : ការការពារនិងការទប់ទល់ ចំពោះការលួច ការប៉ះពាល់ និងការធ្វើឱ្យខូចនាឡិកាស្ទង់**

១-អគ្គិសនីកម្ពុជា (និងធានាថាភ្នាក់ងាររបស់ខ្លួន) ត្រូវធ្វើសកម្មភាពយ៉ាងណាសមស្របដើម្បីការពារ និងទប់ទល់នឹង :

(ក)-ការលួចអគ្គិសនីនៅចំណុចផ្គត់ផ្គង់

(ខ)-ការធ្វើឱ្យខូចខាតបរិក្ខាអគ្គិសនី ខ្សែបណ្តាញឬនាឡិកាស្ទង់ណាមួយដែលតាមរយៈវាអតិថិជនបានទទួលការផ្គត់ផ្គង់

(គ)-ការប៉ះពាល់ដល់នាឡិកាស្ទង់ណាមួយ ដែលតាមរយៈនាឡិកាស្ទង់នេះ គេបានធ្វើការផ្គត់ផ្គង់ឱ្យអតិថិជន ។

២-អគ្គិសនីកម្ពុជាត្រូវបញ្ចូលក្នុងបញ្ញត្តិនៃកិច្ចសន្យាផ្គត់ផ្គង់ជាមួយអតិថិជនថាអតិថិជនត្រូវផ្តល់ពត៌មានឱ្យបានឆាប់រហ័សតាមដែលអាចអនុវត្ត ទៅបានឱ្យអគ្គិសនីកម្ពុជានូវឧប្បត្តិហេតុណាមួយ ដែលគេជឿជាក់ថា :

(ក)-មានការខូចខាតបរិក្ខាអគ្គិសនី ខ្សែបណ្តាញ ឬ នាឡិកាស្ទង់ អគ្គិសនី ឬ

(ខ)-មានការប៉ះពាល់នាឡិកាស្ទង់ដោយធ្វើឱ្យលំអៀងដល់ការកត់ត្រា ឬ ទប់ស្កាត់មិនឱ្យកត់ត្រាបរិមាណអគ្គិសនីដែលបានផ្គត់ផ្គង់។

**លក្ខខណ្ឌទី៥: លក្ខខណ្ឌរៀបចំកូដប្រព័ន្ធចែកចាយ**

១-អគ្គិសនីកម្ពុជា ត្រូវរៀបចំកូដប្រព័ន្ធចែកចាយរបស់ខ្លួន និងផ្ញើជូនអាជ្ញាធរអគ្គិសនីកម្ពុជា ដើម្បីស្នើសុំការអនុម័ត ។ បន្ទាប់ពីការអនុម័តរបស់អាជ្ញាធរ កូដប្រព័ន្ធចែកចាយនេះត្រូវចូលជាធរមាន រួចអគ្គិសនីកម្ពុជាត្រូវតែអនុវត្ត និងគោរពតាមកូដប្រព័ន្ធចែកចាយនេះ ។

២-អគ្គិសនីកម្ពុជាត្រូវពិនិត្យឡើងវិញជាប្រចាំ (ដោយគិតទាំងសំណូមពររបស់អាជ្ញាធរអគ្គិសនីកម្ពុជា)នូវកូដប្រព័ន្ធចែកចាយនិងការអនុវត្តន៍របស់វា។

៣-ការកែសំរួលកូដប្រព័ន្ធចែកចាយ ដែលសំណូមពរដោយអគ្គិសនីកម្ពុជា ត្រូវទាមទារការអនុម័តពីអាជ្ញាធរអគ្គិសនីកម្ពុជា ។

៤-អាជ្ញាធរអគ្គិសនីកម្ពុជា (បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយអគ្គិសនីកម្ពុជា) អាចចេញលិខិតណែនាំបន្ធូរបន្ថយកាតព្វកិច្ចរបស់អគ្គិសនីកម្ពុជា ក្នុងក្របខ័ណ្ឌកូដប្រព័ន្ធចែកចាយចំពោះផ្នែកខ្លះនៃប្រព័ន្ធចែកចាយរបស់អគ្គិសនីកម្ពុជា និងតាមទំហំណាមួយដែលបានកំណត់ក្នុងលិខិតណែនាំ។

**លក្ខខណ្ឌទី៦: ស្តង់ដាប្រតិបត្តិ**

១-អគ្គិសនីកម្ពុជាត្រូវដំណើរការការផ្គត់ផ្គង់ និងការចែកចាយរបស់ខ្លួនតាមស្តង់ដាប្រតិបត្តិមួយ ដែលកំណត់ដោយអាជ្ញាធរអគ្គិសនីកម្ពុជា អនុលោមតាមមាត្រា៣ និង ៧(ង) របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ។

**លក្ខខណ្ឌទី៧: នីតិវិធីដោះស្រាយពាក្យបណ្តឹង**

១-អគ្គិសនីកម្ពុជាត្រូវរៀបចំ និងដាក់ជូនអាជ្ញាធរអគ្គិសនីកម្ពុជា ដើម្បីស្នើសុំការយល់ព្រមលើនីតិវិធីរបស់ខ្លួនសំរាប់ដោះស្រាយពាក្យបណ្តឹង របស់អតិថិជនចំពោះខ្លួន ។

**លក្ខខណ្ឌទី៨: ការបោះបង់ចោលអចលនទ្រព្យ**

១-អគ្គិសនីកម្ពុជាមិនត្រូវបោះបង់ចោល ឬបដិសេធចោលការគ្រប់គ្រងដំណើរការលើអចលនទ្រព្យអាជីវកម្មណាមួយមុនពេលមានការឯកភាព ពីអាជ្ញាធរអគ្គិសនីកម្ពុជាឡើយ ។ "អចលនទ្រព្យអាជីវកម្ម" មានន័យថាគឺជាអចលនទ្រព្យណាមួយដែលនៅពេលនោះជាផ្នែកមួយនៃប្រព័ន្ធចែកចាយរបស់អគ្គិសនីកម្ពុជាមជ្ឈមណ្ឌលបញ្ជាណាមួយដែលប្រើប្រាស់ជាមួយប្រព័ន្ធចែកចាយនោះ និងសិទ្ធិ កម្មសិទ្ធិ ឬអត្ថប្រយោជន៍ណាមួយលើដីដែលអចលនទ្រព្យនោះស្ថិតនៅ ។

២-អគ្គិសនីកម្ពុជា ត្រូវផ្តល់ឱ្យអាជ្ញាធរនូវសំណើជាលាយលក្ខណ៍អក្សរស្តីពីគោលបំណងរបស់គេក្នុងការបោះបង់ចោល ឬបដិសេធចោលការគ្រប់គ្រងដំណើរការលើអចលនទ្រព្យអាជីវកម្មណាមួយ ដោយភ្ជាប់ជាមួយពត៌មានបន្ថែមផ្សេងៗទៀតតាមដែលអាជ្ញាធរស្នើសុំពាក់ព័ន្ធជាមួយ នឹងអចលនទ្រព្យនោះឬកាលៈទេសៈនៃការលះបង់ ឬបដិសេធចោលការគ្រប់គ្រងនេះ ឬគោលបំណងនៃបុគ្គលណាមួយ ដែលចង់ទទួលយក ឬទទួលគ្រប់គ្រងដំណើរការលើអចលនទ្រព្យនោះ ។

៣-អាជ្ញាធរអគ្គិសនីកម្ពុជា (បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយអគ្គិសនីកម្ពុជា) អាចយល់ព្រម ឬមិនយល់ព្រមនូវសំណើនេះ ។

**ល័ក្ខខ័ណ្ឌទី៩: ការគោរពកូដប្រព័ន្ធបញ្ជូន**

១-អគ្គិសនីកម្ពុជាត្រូវគោរពតាមបញ្ញត្តិទាំងឡាយនៃកូដប្រព័ន្ធបញ្ជូនក្នុងកំរិតមួយ ដែលត្រូវអនុវត្តចំពោះអាជីវកម្មរបស់អគ្គិសនីកម្ពុជា ។

២-អាជ្ញាធរអគ្គិសនីកម្ពុជា (បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយអគ្គិសនីកម្ពុជា)អាចចេញលិខិតណែនាំបន្ធូរបន្ថយកាតព្វកិច្ចរបស់អគ្គិសនីកម្ពុជា តាមវាក្យខ័ណ្ឌទី១ ចំពោះផ្នែកណាមួយនៃកូដប្រព័ន្ធបញ្ជូន និងតាមទំហំណាមួយ ដែលកំណត់ក្នុងលិខិតណែនាំ ។

**ល័ក្ខខ័ណ្ឌទី១០: ការគោរពវិធានស្តីពីល័ក្ខខ័ណ្ឌនៃការផ្គត់ផ្គង់**

១-អគ្គិសនីកម្ពុជា ត្រូវគោរពតាមបទប្បញ្ញត្តិទាំងឡាយនៃវិធានស្តីពីល័ក្ខខ័ណ្ឌនៃការផ្គត់ផ្គង់អគ្គិសនីឱ្យអ្នកប្រើប្រាស់ក្នុងព្រះរាជាណាចក្រ កម្ពុជា ដែលចេញដោយអាជ្ញាធរអគ្គិសនីកម្ពុជា ។

២-ក្នុងករណី និង ក្នុងតំបន់ជាក់លាក់ណាមួយអាជ្ញាធរអគ្គិសនីកម្ពុជា (បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយអគ្គិសនីកម្ពុជា) អាចចេញលិខិតណែនាំបន្ធូរបន្ថយកាតព្វកិច្ចរបស់អគ្គិសនីកម្ពុជា តាមវាក្យខ័ណ្ឌទី១ ចំពោះផ្នែកណាមួយនៃវិធានស្តីពីល័ក្ខខ័ណ្ឌនៃការផ្គត់ផ្គង់ និងតាមទំហំ ណាមួយដែលកំណត់ក្នុងលិខិតណែនាំ ។

## ជំពូកទី៥

**ល័ក្ខខ័ណ្ឌនៃការតភ្ជាប់ និងការផ្គត់ផ្គង់សំរាប់អាជ្ញាប័ណ្ណបញ្ជូន និងអាជ្ញាប័ណ្ណចែកចាយ**

**ល័ក្ខខ័ណ្ឌទី១: ល័ក្ខខ័ណ្ឌជាមូលដ្ឋានសំរាប់ផ្គត់ផ្គង់ និងលក់អគ្គិសនីឱ្យអ្នក ចែកចាយមួយទៀត ឬ អ្នកប្រើប្រាស់ធំ**

**ការរៀបចំឯកសារស្តីពីថ្លៃតភ្ជាប់**

១-អគ្គិសនីកម្ពុជាក្នុងពេលដ៏ឆាប់ដែលអាចអនុវត្តបាន ត្រូវរៀបចំឯកសារស្នើសុំការអនុម័តពីអាជ្ញាធរអគ្គិសនីកម្ពុជាស្តីពីមូលដ្ឋាននៃថ្លៃដែលត្រូវ បង់សំរាប់ការតភ្ជាប់ជាមួយប្រព័ន្ធរបស់អគ្គិសនីកម្ពុជា ។

**ការរៀបចំឯកសារស្តីពីលទ្ធភាពអានុភាពប្រព័ន្ធ**

២-អគ្គិសនីកម្ពុជា ក្នុងពេលដ៏ឆាប់ដែលអាចអនុវត្តបានត្រូវរៀបចំនូវឯកសារដែលបង្ហាញក្នុងឆ្នាំនីមួយៗ នៃ៧ឆ្នាំជាបន្តបន្ទាប់នូវអានុភាពនៃ សៀគ្វី ការទស្សន៍ទាយចរន្តឆ្លងកាត់បន្ទុកលើផ្នែកនីមួយៗនៃប្រព័ន្ធបញ្ជូន និងប្រព័ន្ធចែកចាយកំរិតគួរសៀគ្វីត្រង់ចំណុចនីមួយៗនៃប្រព័ន្ធបញ្ជូន និងប្រព័ន្ធចែកចាយជាមួយនឹង :

(ក)-ពត៌មានបន្ថែមទៀត ដែលចាំបាច់និងសមស្របអាចឱ្យបុគ្គលណាមួយដែលមានបំណងតភ្ជាប់ជាមួយប្រព័ន្ធធ្វើការកំណត់ និងវាយតំលៃμកាសដែលអាចមានក្នុងការតភ្ជាប់ និងប្រើប្រាស់ប្រព័ន្ធនោះ,

(ខ)-សេចក្តីអធិប្បាយ ដែលរៀបចំដោយអគ្គិសនីកម្ពុជាបញ្ជាក់នូវទស្សនៈរបស់អគ្គិសនីកម្ពុជាចំពោះផ្នែកណានៃប្រព័ន្ធបញ្ជូន និងប្រព័ន្ធចែកចាយ ដែលសមស្របជាងគេសំរាប់ចំណុចតភ្ជាប់ថ្មី និង

(គ)-បញ្ហាដទៃទៀត ដែលមានកំណត់ក្នុងលិខិតណែនាំចេញដោយ អាជ្ញាធរអគ្គិសនីកម្ពុជាជាបន្តបន្ទាប់ក្នុងគោលដៅនៃល័ក្ខខ័ណ្ឌនេះ។

**ថ្លៃលក់អគ្គិសនីសំរាប់អ្នកចែកចាយមួយទៀត ឬ អ្នកប្រើប្រាស់ដុំ**

៣-អគ្គិសនីកម្ពុជាក្នុងពេលដ៏ឆាប់តាមដែលអាចអនុវត្តបានត្រូវរៀបចំស្នើសុំការអនុម័ត ពីអាជ្ញាធរអគ្គិសនីកម្ពុជានូវឯកសារកំណត់ថ្លៃលក់សំរាប់ការផ្គត់ផ្គង់អគ្គិសនីឱ្យអ្នកចែកចាយផ្សេងទៀតឬអ្នកប្រើប្រាស់ដុំ ។

**ការកែតម្រូវឯកសារ**

៤-អគ្គិសនីកម្ពុជាអាចកែតម្រូវឯកសារទាំងអស់ជាប្រចាំ ដោយអនុលោមតាមលក្ខខ័ណ្ឌនេះ និងយ៉ាងយូរបំផុតក្នុងមួយឆ្នាំម្តង ត្រូវធ្វើការកែសំរួលខ្លឹមសារចាំបាច់ណាមួយចំពោះឯកសារនោះក្នុងគោលបំណង ដើម្បីឱ្យពត៌មានដែលកំណត់ក្នុងឯកសារទាំងនោះមានភាពត្រឹមត្រូវបន្តទៀត ។

៥-អគ្គិសនីកម្ពុជាត្រូវផ្ញើឯកសារ ដែលបានកែតម្រូវរួចនោះមួយច្បាប់ជូនអាជ្ញាធរអគ្គិសនីកម្ពុជា ។ ការកែតម្រូវនីមួយៗត្រូវទាមទារការអនុម័ត ពីអាជ្ញាធរអគ្គិសនីកម្ពុជា និង មិនអាចចូលជាធរមាន មុនពេលអាជ្ញាធរអគ្គិសនីកម្ពុជាបានអនុម័តឡើយ ។

**លក្ខខ័ណ្ឌទី២: ការមិនរើសអើងក្នុងការផ្គត់ផ្គង់អគ្គិសនី និងតភ្ជាប់ជាមួយប្រព័ន្ធ**

១-ក្នុងការផ្គត់ផ្គង់អគ្គិសនីឬក៏ក្នុងការអនុវត្តនីនូវការងារដើម្បីគោលបំណងតភ្ជាប់ជាមួយប្រព័ន្ធរបស់អគ្គិសនីកម្ពុជាឬក្នុងការរក្សាទុកការតភ្ជាប់ ណាមួយជាមួយប្រព័ន្ធរបស់ខ្លួន អគ្គិសនីកម្ពុជាមិនត្រូវរើសអើង :

(ក)-រវាងបុគ្គល ឬក្រុមបុគ្គលណាមួយជាមួយបុគ្គលឬក្រុមបុគ្គលណាមួយទៀតឡើយ, ឬ

(ខ)-រវាងអគ្គិសនីកម្ពុជា និងបុគ្គលណាមួយ ឬក្រុមបុគ្គលណាមួយទៀតឡើយ ។

**លក្ខខ័ណ្ឌទី៣: ការទាមទារផ្តល់លក្ខខ័ណ្ឌកិច្ចសន្យា**

**ការផ្តល់កិច្ចព្រមព្រៀងសំរាប់ការតភ្ជាប់ នៃអ្នកចែកចាយមួយទៀត និង អ្នកប្រើប្រាស់ដុំជាមួយប្រព័ន្ធ របស់អគ្គិសនីកម្ពុជា**

១-ចំពោះការស្នើសុំរបស់បុគ្គលណាមួយ អគ្គិសនីកម្ពុជាត្រូវផ្តល់នូវកិច្ចព្រមព្រៀងមួយសំរាប់ការតភ្ជាប់ ឬការកែតម្រូវនៃការតភ្ជាប់ដែលមានស្រាប់ជាមួយប្រព័ន្ធរបស់អគ្គិសនីកម្ពុជា ។

២-ក្នុងគោលបំណងដើម្បីកំណត់សមាមាត្រសមស្របមួយនៃថ្លៃចំណាយ ដែលចូលរួមផ្ទាល់ និងមិនផ្ទាល់ក្នុងការអនុវត្តនីកិច្ចការក្នុងក្របខ័ណ្ឌកិច្ចព្រមព្រៀងសំរាប់ការតភ្ជាប់ ឬការកែតម្រូវការតភ្ជាប់ចាស់ អគ្គិសនីកម្ពុជាត្រូវយកចិត្តទុកដាក់លើ :

(ក)-អត្ថប្រយោជន៏ (បើសិនជាមាន) ដែលបានទទួល ឬអាចនឹងទទួលបាននាពេលអនាគតដោយអគ្គិសនីកម្ពុជាឬបុគ្គលណាមួយផ្សេងទៀត ដោយសារលទ្ធផលនៃការអនុវត្តនីការងារនោះទោះជា ដោយមូលហេតុនៃការបង្កើនសមត្ថភាព ឬការពង្រីកប្រព័ន្ធរបស់អគ្គិសនីកម្ពុជា ឬការផ្តល់ចំណុចតភ្ជាប់បន្ថែមទៀតលើប្រព័ន្ធនោះឬផ្សេងទៀតក៏ដោយ

(ខ)-លទ្ធភាព ឬលទ្ធភាពទៅអនាគតរបស់អគ្គិសនីកម្ពុជា ដើម្បីទទួលមកវិញនូវផ្នែកមួយនៃ ថ្លៃចំណាយពីភាគីទី៣, និង

(គ)-គោលការណ៏ សំរាប់ការតភ្ជាប់ជាមួយប្រព័ន្ធចែកចាយរបស់អគ្គិសនីកម្ពុជា :

(១)-មិនត្រូវគិតកំរៃ សំរាប់ការបង្កើនសមត្ថភាពនៃប្រព័ន្ធចែកចាយ ដែលមានស្រាប់ ប្រសិនបើប្រព័ន្ធថ្មី ឬកំណើនបន្ទុកដែលត្រូវការមិនលើសពី២៥ភាគរយនៃអានុភាពចាស់នៅត្រង់ចំណុចសមស្របលើប្រព័ន្ធ និង

(២)-ថ្ងៃដែលត្រូវបង់ ជាទូទៅមិនត្រូវគិតបញ្ចូលនូវការបង្កើនសមត្ថភាពនៃប្រព័ន្ធចែកចាយ ដែលបានធ្វើលើកំរិតតង់ស្យុងមួយកំរិតខ្ពស់ជាង កំរិតតង់ស្យុង តភ្ជាប់នោះទេ ។

**ការផ្តល់ល័ក្ខខ័ណ្ឌកិច្ចព្រមព្រៀងសំរាប់ការផ្គត់ផ្គង់ ឬ លក់អគ្គិសនី**

៣-អគ្គិសនីកម្ពុជាត្រូវចុះកិច្ចព្រមព្រៀងជាមួយបុគ្គលណាមួយ ដែលបានស្នើសុំអគ្គិសនីកម្ពុជាឱ្យផ្គត់ផ្គង់ ឬលក់អគ្គិសនីឱ្យគេ កិច្ចព្រមព្រៀងនេះ ត្រូវមានបញ្ញត្តិសំរាប់ថ្លៃលក់ និងបន្ទុកសេវាចំពោះការផ្គត់ផ្គង់ និងលក់អគ្គិសនី ។

**ល័ក្ខខ័ណ្ឌទី៤: ស្តង់ដាល័ក្ខខ័ណ្ឌនៃការតភ្ជាប់ និងការផ្គត់ផ្គង់សំរាប់អ្នកចែកចាយ ផ្សេងទៀត និងអ្នកប្រើប្រាស់ដុំ**

១-អគ្គិសនីកម្ពុជាត្រូវរៀបចំ និងដាក់ជូនអាជ្ញាធរអគ្គិសនីកម្ពុជា ដើម្បីស្នើសុំការអនុម័តនូវ "ស្តង់ដាល័ក្ខខ័ណ្ឌនៃការតភ្ជាប់និងការផ្គត់ផ្គង់" ។

២-អគ្គិសនីកម្ពុជាតាមការអនុម័តរបស់អាជ្ញាធរអគ្គិសនីកម្ពុជាអាចរៀបចំស្តង់ដាល័ក្ខខ័ណ្ឌនៃការតភ្ជាប់ និងការផ្គត់ផ្គង់ខុសៗគ្នាសំរាប់ករណី ឬ ប្រភេទទីតាំងផ្សេងគ្នា, កំណត់ឱ្យច្បាស់លាស់នូវលក្ខណៈវិនិច្ឆ័យដែលប្រើប្រាស់សំរាប់កំណត់ភាពខុសគ្នានៃករណី និងប្រភេទនីមួយៗ ។

៣-អគ្គិសនីកម្ពុជាជាបន្តបន្ទាប់ ទោះជាមាន ឬមិនមានការស្នើសុំពីអាជ្ញាធរអគ្គិសនីកម្ពុជាក៏ដោយ ត្រូវត្រួតពិនិត្យឡើងវិញ នូវស្តង់ដាល័ក្ខខ័ណ្ឌនៃការតភ្ជាប់ និងការផ្គត់ផ្គង់ជាមួយការពិនិត្យមើលដើម្បីកំណត់ថាតើត្រូវធ្វើការកែសំរួលណាមួយលើល័ក្ខខ័ណ្ឌនេះទេ និងក្នុងការពិនិត្យឡើងវិញនេះអគ្គិសនីកម្ពុជា ក៏ត្រូវបានពិគ្រោះយោបល់ជាមួយអ្នកចែកចាយផ្សេងទៀត។

៤-ក្រោយពេលធ្វើការសន្និដ្ឋានលើការពិនិត្យឡើងវិញណាមួយ អនុលោមតាមវាក្យខ័ណ្ឌទី៣ អគ្គិសនីកម្ពុជាត្រូវដាក់ជូនអាជ្ញាធរនូវ :

(ក)-សំណើកែសំរួលស្តង់ដាល័ក្ខខ័ណ្ឌនៃការតភ្ជាប់ និងផ្គត់ផ្គង់ (ឬនៅកន្លែងដែលអគ្គិសនីកម្ពុជាចាត់ទុកថាវាសមស្របសំរាប់គ្រប់កាលៈទេសៈ ហើយអាចសំណូមពរមិនបាច់កែសំរួលស្តង់ដាល័ក្ខខ័ណ្ឌនៃការតភ្ជាប់ និងការផ្គត់ផ្គង់) និង

(ខ)-មូលហេតុនៃសំណើរបស់ខ្លួនជាមួយគ្នានឹងសេចក្តីសង្ខេបនៃចម្លើយ ដែលបានទទួលពីភាគីដែលបានពិគ្រោះយោបល់ដោយអគ្គិសនីកម្ពុជា ។

៥-សំណើដែលធ្វើឡើងដោយអគ្គិសនីកម្ពុជា អនុលោមតាមវាក្យខ័ណ្ឌទី៤ ត្រូវទាមទារការអនុម័តពីអាជ្ញាធរអគ្គិសនីកម្ពុជានិងបន្ទាប់ពីការអនុម័តជាលាយលក្ខណ៍អក្សរ អគ្គិសនីកម្ពុជាត្រូវធ្វើការកែតម្រូវស្តង់ដាល័ក្ខខ័ណ្ឌនៃការតភ្ជាប់នោះ ។

**ល័ក្ខខ័ណ្ឌទី៥ : ភារកិច្ចរបស់អាជ្ញាធរអគ្គិសនីកម្ពុជា**

១-ប្រសិនបើ បន្ទាប់ពីរយៈពេលមួយដែលអាជ្ញាធរអគ្គិសនីកម្ពុជាយល់ថាសមស្រប អគ្គិសនីកម្ពុជានៅតែខកខានមិនបានចុះកិច្ចព្រមព្រៀងជាមួយបុគ្គលណាមួយដែលជាអ្នកចែកចាយឬអ្នកប្រើប្រាស់ដុំ ដែលបានទាមទារ ឬស្នើសុំសិទ្ធិក្នុងការតភ្ជាប់ និងផ្គត់ផ្គង់ឱ្យខ្លួន, អនុលោមតាមសំណើរបស់បុគ្គលនោះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចសំរេចលើល័ក្ខខ័ណ្ឌទាំងឡាយនៃកិច្ចព្រមព្រៀងដែលមានវិវាទរវាងអគ្គិសនីកម្ពុជា ជាមួយបុគ្គលនោះ ។

២-ប្រសិនបើបុគ្គលណាមួយ ដែលទាមទារ ឬ តវ៉ាសុំសិទ្ធិតភ្ជាប់ និងការផ្គត់ផ្គង់តាមល័ក្ខខ័ណ្ឌទី៤ និងល័ក្ខខ័ណ្ឌទី៥ មានបំណងដំណើរការ ដោយឈរលើមូលដ្ឋាននៃកិច្ចព្រមព្រៀង ដែលបានសំរេចដោយអាជ្ញាធរអគ្គិសនីកម្ពុជាអគ្គិសនីកម្ពុជាត្រូវតែចុះកិច្ចព្រមព្រៀង និងត្រូវតែអនុវត្តកិច្ចព្រមព្រៀងនោះ ដោយអនុលោមតាមល័ក្ខខ័ណ្ឌរបស់វា ។

៣-ប្រសិនបើ ភាគីណាមួយនៃកិច្ចព្រមព្រៀងខាងលើស្នើសុំកែប្រែល័ក្ខខ័ណ្ឌ នៃកិច្ចព្រមព្រៀងសំរាប់ការផ្គត់ផ្គង់សេវាការផ្តល់នូវការតភ្ជាប់ និងការផ្គត់ផ្គង់ ឬសំរាប់ការកែសំរួលការតភ្ជាប់ចាស់ជាមួយប្រព័ន្ធរបស់អគ្គិសនីកម្ពុជាអាជ្ញាធរអគ្គិសនីកម្ពុជាអាចតាមសំណើរបស់ភាគីនោះ ដោះស្រាយវិវាទណាមួយដែលទាក់ទងជាមួយការកែប្រែនេះក្នុងរបៀបរបបមួយដែលអាជ្ញាធរអគ្គិសនីកម្ពុជាចាត់ទុកថាសមស្រប ។

## ឧបសម្ព័ន្ធទី១

### មធ្យោបាយផលិតកម្មដែលមានស្រាប់របស់អគ្គិសនីកម្ពុជា

មធ្យោបាយផលិតកម្មដែលមានស្រាប់របស់អគ្គិសនីកម្ពុជា មានរោងចក្រ អគ្គិសនីដូចខាងក្រោម :

ក- នៅភ្នំពេញ

ខ- នៅទីក្រុងព្រះសីហនុ

គ- នៅសៀមរាប

ឃ- នៅបាត់ដំបង

ង- នៅតាកែវ

ច- នៅបន្ទាយមានជ័យ

ឆ- នៅកំពត

ជ- នៅព្រៃវែង

ឈ- នៅរតនគិរី

ញ- នៅស្ទឹងត្រែង

## ឧបសម្ព័ន្ធទី២

### តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនី

១-តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនីដែលអគ្គិសនីកម្ពុជាមានសិទ្ធិផ្តល់សេវាចែកចាយនិងផ្គត់ផ្គង់អគ្គិសនីមានដូចខាងក្រោម :

(ក) - តំបន់ចែកចាយភ្នំពេញ និងតំបន់ជុំវិញភ្នំពេញ (PNH-DA)

(ខ) - តំបន់ចែកចាយក្រុងព្រះសីហនុ (SHV-DA)

(គ) - តំបន់ចែកចាយទីរួមខេត្តសៀមរាប (SRP-DA)

(ឃ) - តំបន់ចែកចាយទីរួមខេត្តកំពង់ចាម (KCM-DA)

(ង) - តំបន់ចែកចាយទីរួមខេត្តបាត់ដំបង (BBG-DA)

(ច) - តំបន់ចែកចាយទីរួមខេត្តតាកែវ (TKO-DA)

(ឆ) - តំបន់ចែកចាយទីរួមខេត្តបន្ទាយមានជ័យ (BTM-DA)

(ជ) - តំបន់ចែកចាយទឹរួមខេត្តកំពត និងក្រុងកែប (KPK-DA)

(ឈ)- តំបន់ចែកចាយទឹរួមខេត្តស្វាយរៀង (SVR-DA)

(ញ)- តំបន់ចែកចាយទឹរួមខេត្តព្រៃវែង (PRV-DA)

(ដ) - តំបន់ចែកចាយទឹរួមខេត្តកំពង់ស្ពឺ (KSP-DA)

(ឋ) - តំបន់ចែកចាយទឹរួមខេត្តរតនគិរី (RNK-DA)

(ឌ) - តំបន់ចែកចាយទឹរួមខេត្តស្ទឹងត្រែង (STR-DA)

(ឍ) - តំបន់ចែកចាយទឹរួមស្រុកពញ្ញាក្រែកនិងមេមត់ (KR&M-DA) (BVT-DA)

(ណ)-តំបន់ចែកចាយឃុំបាវិត

២-តំបន់ចែកចាយអគ្គិសនីគឺជាតំបន់ដែលមានព្រំដីជាប់គ្នា និងកំណត់ដោយ "ផែនទីកំណត់ព្រំប្រទល់" មានដូចខាងក្រោមៈ

(ក) - ផែនទី PNH-DA-Map

(ខ) - ផែនទី SHV-DA-Map

(គ) - ផែនទី SRP-DA-Map

(ឃ) - ផែនទី KCM-DA-Map

(ង) - ផែនទី BBG-DA-Map

(ច) - ផែនទី TKO-DA-Map

(ឆ) - ផែនទី BTM-DA-Map

(ជ) - ផែនទី KPK-DA-Map

(ឈ)-ផែនទី SVR-DA-Map

(ញ) - ផែនទី PRV-DA-Map

(ដ) - ផែនទី KSP-DA-Map

(ឋ) - ផែនទី RNK-DA-Map

(ឌ) - ផែនទី STR-DA-Map

(ឍ) - ផែនទី KR&M-DA-Map

(ណ)- ផែនទី BVT-DA-Map

# ឧបសម្ព័ន្ធទី២

# តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនី

# ធ្វើការកែសម្រួលជាថ្មី ក្នុងសម័យប្រជុំរបស់អាជ្ញាធរអគ្គិសនីកម្ពុជា

# លើកទី៥៦ នាថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៥

១- តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនី ដែលអគ្គិសនីកម្ពុជាមានសិទ្ធិផ្តល់ សេវាចែកចាយ និងផ្គត់ផ្គង់អគ្គិសនី មានដូចខាងក្រោម :

(ក)-តំបន់ចែកចាយរាជធានីភ្នំពេញ និងតំបន់ជុំវិញ ដែលកំណត់ដោយ ផែនទីកំណត់ព្រំប្រទល់ លេខ EDC-PNH-D-Map-Revised-2

(ខ)-តំបន់ចែកចាយក្រុងព្រះសីហនុ ដែលកំណត់ដោយផែនទីកំណត់ ព្រំប្រទល់ លេខ EDC-SHV-D-Map

(គ)-តំបន់ចែកចាយទីរួមខេត្តសៀមរាប ដែលកំណត់ដោយផែនទី កំណត់ព្រំប្រទល់ លេខ EDC-SRP-D-Map

(ឃ)-តំបន់ចែកចាយទីរួមខេត្តកំពង់ចាម ដែលកំណត់ដោយផែនទី កំណត់ព្រំប្រទល់ លេខ EDC-KCM-D-Map

(ង)-តំបន់ចែកចាយទីរួមខេត្តបាត់ដំបង ដែលកំណត់ដោយផែនទីកំណត់ ព្រំប្រទល់ លេខ EDC-BBG-D-Map-Revised-1

(ច)-តំបន់ចែកចាយទីរួមខេត្តតាកែវ ដែលកំណត់ដោយផែនទីកំណត់ ព្រំប្រទល់ លេខ EDC-TKO-D-Map-Revised-1

(ឆ)-តំបន់ចែកចាយទីរួមខេត្តបន្ទាយមានជ័យ ដែលកំណត់ដោយ ផែនទីកំណត់ព្រំប្រទល់ លេខ EDC-BTM-D-Map Revised-1

(ជ)-តំបន់ចែកចាយទីរួមខេត្តកំពត និងក្រុងកែប ដែលកំណត់ដោយ ផែនទីកំណត់ព្រំប្រទល់ លេខ EDC-KPK-D-Map

(ឈ)-តំបន់ចែកចាយទីរួមខេត្តស្វាយរៀង ដែលកំណត់ដោយផែនទី កំណត់ព្រំប្រទល់ លេខ EDC-SVR-D-Map

(ញ)-តំបន់ចែកចាយទីរួមខេត្តព្រៃវែង ដែលកំណត់ដោយផែនទី កំណត់ព្រំប្រទល់ លេខ EDC-PRV-D-Map

(ដ)-តំបន់ចែកចាយទីរួមខេត្តកំពង់ស្ពឺ ដែលកំណត់ដោយផែនទីកំណត់ ព្រំប្រទល់ លេខ EDC-KSP-D-Map

(ឋ)-តំបន់ចែកចាយទីរួមខេត្តរតនគីរី ដែលកំណត់ដោយផែនទីកំណត់ ព្រំប្រទល់ លេខ EDC-RNK-D-Map

(ឌ)-តំបន់ចែកចាយទីរួមខេត្តស្ទឹងត្រែង (STR-DA) ដែលមានព្រំដីជាប់គ្នា និងកំណត់ដោយផែនទីកំណត់ព្រំប្រទល់ លេខ STR-DA-Map

(ឍ)-តំបន់ចែកចាយទីរួមស្រុកពញាក្រែកនិងមេមត់ ដែលកំណត់ ដោយ ផែនទីកំណត់ព្រំប្រទល់ លេខ EDC-KR&M-D-Map

(ណ)-តំបន់ចែកចាយឃុំបាវិត ដែលកំណត់ដោយផែនទីកំណត់ព្រំ ប្រទល់លេខ EDC-BVT-D-Map

(ត)-តំបន់ចែកចាយទីរួមស្រុកកំពង់ត្រាច ឃុំឬស្សីស្រុកខាងលិច ឃុំកំពង់ត្រាចខាងកើត និង ឃុំកន្ទោរខាងលិច ស្រុកកំពង់ត្រាច ខេត្ត កំពត EDC-KGTr-D-Map-Revised-1

២- អាជ្ញាប័ណ្ណចែកចាយដែលផ្តល់ឱ្យតាមឯកសារនេះ ផ្តល់សិទ្ធិឱ្យអគ្គិសនីកម្ពុជា អាចស្នើសុំពង្រីក ឬស្នើសុំបន្ថែមតំបន់ចែកចាយអគ្គិសនីថែមទៀត យោងតាមគំរោងអភិវឌ្ឍន៍របស់ខ្លួន។

៣- ក្នុងក្របខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ ប្រសិនបើ អគ្គិសនីកម្ពុជាមានបំណងស្នើសុំពង្រីក ឬបន្ថែមតំបន់ចែកចាយថែមទៀត ពេលនោះអគ្គិសនីកម្ពុជា ត្រូវរៀបចំឯកសារចាំបាច់នានា ដាក់ស្នើសុំមកអាជ្ញាធរអគ្គិសនីកម្ពុជា តាមការកំណត់របស់អាជ្ញាធរ។ ក្រោយពេលដែលអាជ្ញាធរអគ្គិសនីកម្ពុជា ចេញសេចក្តីសំរេចអនុញ្ញាតឱ្យពង្រីក ឬបន្ថែមតំបន់ចែកចាយណាមួយ ឧបសម្ព័ន្ធទី២នេះ ត្រូវធ្វើការកែសំរួលដោយភ្ជាប់ជាមួយសេចក្តីសំរេចឱ្យពង្រីកបន្ថែមតំបន់ចែកចាយនោះ។

## ឧបសម្ព័ន្ធទី៣

**ល័ក្ខខ័ណ្ឌសំរាប់ធ្វើការដកហូតអាជ្ញាប័ណ្ណ**

១-អាជ្ញាធរអគ្គិសនីកម្ពុជាអាចធ្វើការដកហូតអាជ្ញាប័ណ្ណណាមួយដែលបានផ្តល់ដោយឯកសារនេះបានគ្រប់ពេលតាមកាលៈទេសៈដូចខាងក្រោម :

(ក)-ប្រសិនបើអគ្គិសនីកម្ពុជា សំណូមពរជាលាយលក្ខណ៍អក្សរ ទៅអាជ្ញាធរអគ្គិសនីកម្ពុជាសុំឱ្យដកហូតអាជ្ញាប័ណ្ណ នេះឬ

(ខ)-ប្រសិនបើចំនួនទឹកប្រាក់ដែលត្រូវបង់ណាមួយតាមល័ក្ខខ័ណ្ឌទី៧ជំពូកទី១ទាក់ទងជាមួយអាជ្ញាប័ណ្ណនេះ មិនបានទូទាត់ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃដែលកំណត់ឱ្យបង់ ឬមិនបានទូទាត់ក្នុងរយៈពេល១៤ ថ្ងៃបន្ទាប់ពីថ្ងៃ ដែលអាជ្ញាធរបានប្រគល់លិខិតជូនដំណឹងឱ្យទៅអគ្គិសនីកម្ពុជាថា ថ្ងៃទូទាត់បានផុតកំណត់ហើយ ប៉ុន្តែលិខិតជូនដំណឹងនេះមិនត្រូវចេញមុន១៦ថ្ងៃ បន្ទាប់ពីថ្ងៃដែលចំនួនទឹកប្រាក់នេះត្រូវកំណត់ឱ្យបង់ឡើយ ។

(គ)-ប្រសិនបើតាមយោបល់របស់អាជ្ញាធរអគ្គិសនីកម្ពុជាអគ្គិសនីកម្ពុជាបានប្រព្រឹត្តិខុសពីល័ក្ខខ័ណ្ឌណាមួយនៃអាជ្ញាប័ណ្ណ និងមិនគោរពតាមបទបញ្ជាចុងក្រោយរបស់អាជ្ញាធរអគ្គិសនីកម្ពុជាក្នុងការកែតម្រូវកំហុសនេះ ឬ

(ឃ)-ប្រសិនបើតាមយោបល់របស់អាជ្ញាធរអគ្គិសនីកម្ពុជា អគ្គិសនីកម្ពុជាមិនបានបំពេញភារកិច្ច និងកាតព្វកិច្ច ដែលបានកំណត់ ដោយអាជ្ញាប័ណ្ណនេះឱ្យបានពេញលេញ និងប្រកបដោយប្រសិទ្ធភាព ឬ

(ង)-ប្រសិនបើតាមយោបល់របស់អាជ្ញាធរអគ្គិសនីកម្ពុជា អគ្គិសនីកម្ពុជាបានប្រព្រឹត្តិខុសដោយចេតនានិងគ្មានហេតុផលចំពោះល័ក្ខខ័ណ្ឌដែលកំណត់ក្នុងវិធាន និងបទប្បញ្ញត្តិ ដែលអនុម័ត ដោយអាជ្ញាធរអគ្គិសនីកម្ពុជា និងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា រួមទាំងច្បាប់ការពារបរិស្ថាន សុវត្ថិភាព សុខភាព ពន្ធដារ ព្រមទាំងការអនុវត្តន៍ការការពារ និងស្តង់ដានៃប្រព័ន្ធអគ្គិសនី។

២-នៅគ្រប់ពេលអាជ្ញាធរអគ្គិសនី អាចចេញសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរ ដោយទុករយៈពេលមិនតិចជាង ៣ខែ ទៅអគ្គិសនីកម្ពុជា ស្តីពីមូលហេតុដែលឈរលើនេះអាជ្ញាប័ណ្ណណាមួយតម្រូវឱ្យដកហូត ។

៣-ជំនួសឱ្យការដកហូតអាជ្ញាប័ណ្ណ អាជ្ញាធរអគ្គិសនីកម្ពុជាអាចអនុញ្ញាតឱ្យអាជ្ញាប័ណ្ណនេះបន្តនៅជាធរមានបន្តទៀត បើសិនជាមានល័ក្ខខ័ណ្ឌ បន្ថែមទៀតដែលយល់ថាគួរត្រូវដាក់ជំនួសរួចល័ក្ខខ័ណ្ឌបន្ថែមដែលត្រូវដាក់នេះត្រូវចងភ្ជាប់តាមផ្លូវច្បាប់ និងត្រូវប្រតិបត្តិតាម ដោយអគ្គិសនីកម្ពុជា និងត្រូវចូលជាធរមានដូចបានកំណត់ក្នុងអាជ្ញាប័ណ្ណ ដូច្នេះដែរ។

៤-អាជ្ញាប័ណ្ណណាមួយអាចត្រូវដកហូត បន្ទាប់ពីបានចេញសេចក្តីជូនដំណឹងដោយទុករយៈពេល ៣ខែ ក្នុងករណីដែលរាជរដ្ឋាភិបាលកម្ពុជា បានចេញបទបញ្ជាឱ្យបំបែកសេវាកម្មផលិតសេវាកម្មបញ្ជូន និងសេវាកម្មចែកចាយរបស់អគ្គិសនីកម្ពុជា ឱ្យដាច់ដោយឡែកពីគ្នាក្នុងគោលដៅជំរុញឱ្យមានប្រសិទ្ធភាព និងមានការប្រកួតប្រជែងដើម្បីចូលរួមកាត់បន្ថយចំណាយម៉ាហ្សូណាល់សំរាប់ដំណើរការរយៈពេលវែង ។